ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១៣-១៤
13 – 14.

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៥
គ.ស. ១៩៤២
1942

# សេចក្ដីជូនដំណឹង

ព្រះពុទ្ធបណ្ឌិត្យ សូមជូនដំណឹងដល់លោក-អ្នកទាំងឡាយ.

ដ្បិតព្រះពុទ្ធបណ្ឌិត្យបានបោះពុម្ពផ្សាយរឿងថ្មី ៗ នឹងបោះពុម្ពសៀវភៅចាស់ដែលចំណាយអស់ទៅ រួមជាច្រើនរឿងដូចមានរាយឈ្មោះខាងក្រោមនេះ:

ចំពោះរឿងដែលបោះពុម្ពថ្មី:

១) ក្រងសុភមិត្រពាក្យកាព្យភាគទី ២ និងទី ៣ តសេចក្ដីពីភាគទី ១ មក ដែលព្រះពុទ្ធបណ្ឌិត្យបានបោះពុម្ពផ្សាយរួចមកហើយកាលពីឆ្នាំមុននេះ ដូច្នេះ អស់លោកដែលបានជាវភាគទី ១ រួចហើយ សូមអញ្ជើញទៅជាវភាគទី ២-៣ ទៀតទើបចប់រឿង ភាគទី ២ នោះដំឡៃជាវ ១ ក្បាល ០រ.៤០ ភាគទី ៣ ដំឡៃ ១ ក្បាល ០រ.៣៥ ។

២) ច្បាប់ផ្សេងៗគឺ: វិធូរបណ្ឌិត ១ ច្បាប់ខ្ញុំនាទខ្លួន ១ ច្បាប់ពាក្យចាស់ ១ រួមគ្នាជាមួយក្បាល ស្រង់ចេញពីច្បាប់សាស្ត្រាស្លឹករឹត ច្បាប់ផ្សេងៗនេះ ១ ក្បាលដំឡៃ ០រ.២០ ។

៣) សុភូតិសូត្រ មានទាំងបាលីទាំងសម្រាយ ជាធម៌សម្រាប់សូត្រសុំទឹកភ្លៀងតាមទំនៀមស្រុក ។ តាមទំនៀមស្រុកខ្មែរពីដើមនោះតែកាលណាស្រុកទេសកើតរាំងភ្លៀងគ្មានទឹកនឹងធ្វើស្រែចំការបានដំណាំអ្នកស្រុកច្រើនតែនិមន្តព្រះសង្ឃឲ្យសូត្រសុភូតិសូត្រនេះ ប៉ុន្តែទំលាប់មាត់អ្នកស្រុកច្រើននិយាយថា "សូត្រសុភោត្ដោ" ។ សៀវភៅនេះដំឡៃ ១ ក្បាល ០រ.២០ ។

៤) ច្បាប់សុភាសិត ពាក្យកាព្យ មានទាំងបាលីទាំងសម្រាយ ជាពាក្យទូន្មានជនប្រុស-ស្រី ជាថ្វីដៃរបស់លោកឧកញ៉ាវង្សាសរពេជ្ញ នង ជាចិន្តកវីជាន់ចាស់ ក្នុងរជ្យព្រះករុណាព្រះបរមកោដ្ឋព្រះអង្គដួង សៀវភៅនេះ ១ ក្បាលដំឡៃ ០រ.២៥ ។

ចំពោះរឿងដែលបោះពុម្ពឡើងវិញ:

១) អត្ថានុសាសនី ជាសេចក្ដីទូន្មានខ្លួនឲ្យតាំងនៅក្នុងសមាបដិបត្តិ តាមព្រះពុទ្ធឱវាទ ដំឡៃថ្មី ១ ក្បាល ០រ.៣៥ ។

២) គតិលោក ភាគទី១ ជាថ្វីដៃរបស់លោកឧកញ៉ាសុត្តន្តប្រីជា អិន ជាចិន្តកវីឯក ក្នុងរជ្យព្រះករុណាស៊ីសុវត្ថិព្រះបរមរាជានុកោដ្ឋ ដំឡៃថ្មី ១ ក្បាល ០រ.២០ ។

៣) បញ្ចអភិណ្ហប្បច្ចវេក្ខណ: ជាធម៌សម្រាប់ឲ្យពុទ្ធសាសនិកជនពិចារណាឲ្យរឿយៗ មាន ៥ ប្រការ ជាស្នាព្រះហស្តសម្ដេចព្រះរាជអយ្យកោ វរចក្រណាបុទ្ធ ដំឡៃថ្មី ១ ក្បាល ០រ.១២ ។

៤) គិហិបដិបត្តិពិស្តារ សំដែងពីវិធីបដិបត្តិរបស់ពួកឧបាសកឧបាសិកាតាមច្បាប់ព្រះពុទ្ធសាសនា សៀវភៅនេះបោះពុម្ពច្រើនលើកមកហើយ ដំឡៃថ្មី ១ ក្បាល ០រ.៥៥ ។

សៀវភៅអស់នេះ មានចំណាយនៅព្រះរាជបណ្ណាល័យកម្ពុជា ទីកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យទូទៅទាំងក្នុងក្រុងនិងខេត្រក្រៅ ។

# បញ្ជីរឿង

ទំព័រ

១ — វិទ្យុធម្មទេសនា កណ្ឌៈទី ៦ លោកគ្រូអាចារ្យ សា-ឌុម ក្រុមជំនុំព្រះត្រៃបិដក សំដែង . . . . . . . . . . . . . . . . . . . . . . . . . . . . . ១
២ — អំពីមហាចិន្តកវីកាលីទាសៈ នឹងកិច្ចការជាថ្មីដែរបស់លោក . . . . . . . . ១១
៣ — ប្រវត្តិពួកឧបាសិកៈ ជាសាវិការបស់ព្រះពុទ្ធជាម្ចាស់ៈ ១ — ប្រវត្តិនាងសុជាតា-សេនិយធីតា . . . . . . . . . . . . . . . . . . . . . . . . . . . . . ២១
៤ — លោកនេយ្យ ពាក្យកាព្យ របស់អ្នកឧកញ៉ាវង្សាសពេជ្ញ ឧង (តមក) . . ២៤
៥ — ពិធីទូ្វទសមាស តាមទំនៀមព្រាហ្មណ៍ក្នុងនគរពារាណសី (ឥណ្ឌៀ) . . . ៣២
៦ — ភូមិសាស្ត្រសង្ខេបនៃនានាប្រទេសៈ អំពីភូមិសាស្ត្រនៃប្រទេសអាមេរិកកណ្ដាល. ៣៥
៧ — ពង្សាវតារក្រុងរោម ស្រង់យកអំពីគោលចារិកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤១
៨ — រឿងព្រះបាទអសោកមហារាជ អ្នកអាចារ្យ គឹម-អាន ប្រែចេញពីភាសាបារាំង-សែសមកជាខេមរភាសា (តមក) . . . . . . . . . . . . . . . . ៤៤
៩ — ប្រស្នាចំរើនសតិបញ្ញាៈ
១) សួរនឹងឆ្លើយអំពីខ្លាក់នឹងទ្វីន (តមកនឹងចប់). . . . . . . . . . ៥៣
២) សួរនឹងឆ្លើយអំពីសក់ . . . . . . . . . . . . . . . . . . . . . . ៥៥
៣) សួរនឹងឆ្លើយអំពីស្វានឹងចារី . . . . . . . . . . . . . . . . . . ៥៧
៤) សួរនឹងឆ្លើយអំពីពុកមាត់ . . . . . . . . . . . . . . . . . . . . ៥៩
១ — រឿងព្រេងខ្មែរៈ "រឿងបុរសបាញ់ទុង" . . . . . . . . . . . . . . . . ៦១

# TABLE DES MATIÈRES

Pages

1. Vidyudesanā (Conférence faite à la Radio Phnom-Penh) par le vénérable Sa-Doum, membre de la Commission du Tripitaka .......... 1

2. Kalidāsā, grand poète de l'Inde, et ses œuvres.......... 11

3. Vies des disciples du Bouddha: I. Vie du Sujatā-Seniyadhitā. 21

4. Lokaneyya, poème par feu l'Oknha Vongsāsarpejña Nong (suite).......... 24

5. Cérémonies brahmaniques des douze mois à Bénarès (Inde).. 32

6. Géographie sommaire de divers pays: l'Amérique centrale... 35

7. Histoire de Rome, extraits de divers documents de l'histoires universelle (suite).......... 41

8. Légende de l'Empereur Açoka de l'Inde antique, par feu l'Achar Kim-Ann (suite).......... 44

9. Réflexions sur les phénomènes naturels:

I. Dialogue sur l'aveugle et le paralytique (suite et fin)... 53

II. Dialogue sur les cheveux.......... 55

III. Dialogue sur la fumée de cigarette et la chique de bétel.......... 57

IV. Dialogue sur les barbes.......... 59

10. Conte populaire cambodgien inédit: " Un chasseur de péli-

វិទ្យុឧទ្ទេសនា កណ្ឌទី ៦

លោកគ្រូអាចារ្យ សា-ឌុម ក្រុមជំនុំព្រះត្រៃបិដក សំដែង

នៅថ្ងៃពុធ ៨ រោច ខែចេត្រ ឆ្នាំម្សាញ់ត្រីស័ក ពុទ្ធសករាជ ២៤៩៤ ។

## សន្តិកថា

សន្តិមគ្គមេវ ព្រូហយ ។

វេលានេះ នឹងពណ៌នាអំពីសន្តិភាព (សេចក្ដីស្ងប់) ដែលរាប់ថាជាកំពូលនៃសេចក្ដីសុខយ៉ាងសំខាន់ ដើម្បីឲ្យត្រូវតាមបំណងពុទ្ធសាសនា ។ ឥឡូវនេះ នៅសេសចំនួន ៤-៥ ថ្ងៃទៀតទេ នឹងដល់កំរិតលះឆ្នាំចាស់ចូលឆ្នាំថ្មី ៗ

សម័យនេះហើយ ដែលពួកយើងគួរប្រែគំនិតដែលធ្លាប់ពុលដោយល្បែងស្រី ល្បែងស្រា និងល្បែងបៀជាដើមពីឆ្នាំចាស់ ផ្លាស់ឲ្យបានជាគំនិតថ្មីជាល្អវិញ ។ សម័យនេះហើយ ដែលពួកយើងត្រូវស្វែងរកសេចក្ដីស្ងប់ ដោយការពួតដៃវេញចូលផ្គុំគ្នាជាពួក ។ សម័យនេះហើយ ដែលពួកយើងត្រូវតាំងចិត្តមេត្តាក្រឡេកមើលគ្នាដោយនេត្រាដ៏ស្រទន់ មិនរិះគន់រកទោសគ្នាទៅវិញទៅមក ។ សម័យនេះហើយដែលពួកយើងត្រូវរឭកដល់គុណនៃគ្នានឹងគ្នា ជាគ្រឿងបង្កឲ្យកើតសាមគ្គីស្មោះស័គ្រប្រឹងស្វែងរកសេចក្ដីស្ងប់ ។

ផនជាន់ណាក៏ដោយ ឲ្យតែមានកំណើតកើតឡើងអាស្រ័យចតុភូត គឺ ដី ទឹក ភ្លើង ខ្យល់ហើយ សុទ្ធតែមានអធ្យាស្រ័យស្រឡាញ់សេចក្ដីសុខ ស្អប់ខ្ពើមទុក្ខទាំងអស់ ។ សេចក្ដីទុក្ខជាគ្រឿងបង្អើលឲ្យស្វែងរកសុខ ស្អប់ខ្ពើមទុក្ខទាំងអស់ ។ សេចក្ដីសុខជាគ្រឿងបង្អើលឲ្យស្វែងរកព្រះនិព្វាន ។ បើទុកជាមានលំនាំយ៉ាងនេះក្ដី ក៏គង់នៅមានជនជាច្រើនស្ទើរតែពេញលោក ប្រែត្រឡប់ជាខំខ្នះខ្នែងស្វែងរកសេចក្ដីសុខមិនបានបេះតែឃ្លាងផ្លូវដកថយទៅវិញ ។ ទាំងនេះ មកពីមិនមានគំនិតធ្លុះមុតយល់ដល់មូលហេតុ ដែលជាដើមចមនៃសេចក្ដីសុខ មានជនខ្លះថែមទាំងមិនស្គាល់សេចក្ដីសុខទៅទៀតផង ។ យ៉ាងនេះតើកាលណាទើបស្វែងរកសេចក្ដីសុខបាន ព្រោះសេចក្ដីសុខចាត់ដោយប្រភេទមាន ២ យ៉ាងគឺសេចក្ដីសុខប្លម ដែលហៅថា សាមិសសុខ (សុខអាស្រ័យនុយ) មួយយ៉ាង សេចក្ដីសុខពិត ដែលហៅថា និរាមិសសុខ (សុខមិនអាស្រ័យនុយ) មួយយ៉ាង ។

ចុះនុយបានដល់អ្វី? នុយបានដល់លាភ យស សរសើរ សុខ ឬ រូប សំឡេង ក្លិន រស ផស្សៈ ដែលជាទីប្រាថ្នា ។ សេចក្ដីត្រេកត្រអាលជក់ចិត្តក្នុងនុយទាំងនោះ ចាត់ជាសេចក្ដីសុខប្លម ព្រោះវាមិនប្រែក្លាយទៅជាសេចក្ដីតូចចិត្តទោមនស្សស្រោកអន្ទះអន្ទាញវិញ ។

វិញ្ញូជនគួរឃើញថា ដូចសេចក្ដីសុខរបស់ត្រី ដែលត្រេកត្រអាលប្រឹងលេបនុយដោយទាំងសន្ទូច ល្មមយល់ថាឲ្យសុខមែន តែក្នុងវេលា

ដែលប្រឹងផ្ញាក់ផ្ញាបលេបមនុស្ស រួចហើយគង់ប្រែត្រឡប់ទៅជាសេចក្ដីទុក្ខវិញ ក្នុងវេលាដែលសន្ធូបជាប់ក ។ ដំណើរនេះ នាំឲ្យឃើញច្បាស់ដល់ព្រះបាលីថា . សុខស្សានន្តរំ ទុក្ខំ សេចក្ដីទុក្ខកើតជាប់-ជាប់នៃសេចក្ដីសុខ គឺថាសេចក្ដីសុខកើតមានហើយ គង់ប្រែខ្វៃទៅជាសេចក្ដីទុក្ខវិញ ។ សេចក្ដីសុខបួមបែបនេះ អ្នកប្រាជ្ញខាងពុទ្ធសាសនាមិនត្រូវការ គឺមិនបណ្ដោយចិត្តឲ្យទទួលរីករាយ ដោយសំគាល់ថា ជាសេចក្ដីសុខមែន លោកតែងនាំគ្នាបោះបង់ចោល ហើយប្រឹងស្វះស្វែងរកតែសេច-ក្ដីសុខពិតឥតប្រែក្លាយ ដែលជាតួនិរាមិសសុខ (សុខមិនអាស្រ័យនុយ) គឺថាមិនបាច់ដើរមើលល្បែងក៏សុខ មិនបាច់លេងបៀ ផឹកស្រា . ជក់អាភៀនក៏សុខ មិនបាច់ដើរលេងស្រីឬមានប្រពន្ធច្រើនក៏សុខ ដរាបដល់មិនបាច់មានប្រពន្ធមានកូនសោះក៏សុខ ។ មួយទៀត សេចក្ដីសុខនេះ កើតមានឡើងអាស្រ័យសេចក្ដីស្ងប់ៗរាប់ថាជាកំពូលឬជាមូលហេតុនៃសេចក្ដីសុខៗ ដំណើរនេះ អាចធៀបបានដោយផ្លូវលោក ចំណោមជនដែលនៅរួមគ្នាជាពួកៗ តាំងអំពីនៅរួមគ្នាជាប្ដីប្រពន្ធឡើងទៅ ដរាបដល់ការនៅរួមឃុំ រួមខេត្ត រួមក្រុង រួមដែន និងរួមកិច្ចការជួញប្រែ ដែលត្រូវអាស្រ័យគ្នា និងទាក់ទិនគ្នាទៅវិញទៅមក បើប្រសិនជាគ្មានសេចក្ដីស្ងប់ គឺថាចេះតែច្រួលច្រើមដោយវិវាទបែកសាមគ្គី រករឿងចាប់ទោសអួសដំណើរគ្នាជារឿយៗហើយ មុខជានឹងមានតែសេចក្ដីទុក្ខ រកសេចក្ដីសុខគ្មាន ។

ហេតុនេះ បានជាអ្នកប្រាជ្ញមានព្រះសព្វញ្ញុពុទ្ធជាដើម តែងនាំគ្នាស្វែងរកឧបាយធ្វើឲ្យកើតសេចក្ដីស្ងប់ គឺប្រដៅឲ្យធ្វើទានចែកសេចក្ដីសុខដល់គ្នានឹងគ្នា ធ្វើសមាធិហាត់ចិត្តឲ្យស្ងប់ មិនឲ្យពុះក្ដៅដោយសេចក្ដីលោភ ក្រោធ វង្វេង ធ្វើបញ្ញាពិចារណាកងសង្ខារដកបចុះចិត្តសិបថា មិនទៀងជាទុក្ខនឹងអនត្តា គ្រាន់តែពុះបំបែកនូវឧបាទាន (សេចក្ដីប្រកាន់មាំ) ថារបស់អញ ថាអញ ជាខ្លួនប្រាណនៃអញ ដែលជាមេបង្កឲ្យឆួលឆេះក្ដៅក្រហាយរេញ ៗ ព្រោះ ទាន សីល ភាវនានេះ មានគុណយ៉ាងសំខាន់ ទាំងនាំបណ្ដាលឲ្យកើតសេចក្ដីស្ងប់ល្អ បានជាព្រះសាស្ដាទ្រង់ប្រោសប្រទានទុកទុកថា សន្តិមគ្គមេវ ព្រូហយ អ្នកចូរប្រឹងបំពេញតែឧបាយនៃសេចក្ដីស្ងប់ គឺ ទាន សីល ភាវនា ចុះ នត្ថិ សន្តិ-បរំ សុខំ (ព្រោះ) សេចក្ដីសុខដទៃក្រៅពីសេចក្ដីស្ងប់មិនមាន គឺថាមានសេចក្ដីស្ងប់ជាកំពូល ឬជាមូលហេតុទាំងអស់ ៗ ពួកយើងគួរខ្មីឃ្មាតរកឧបាយសាងសេចក្ដីស្ងប់ ដោយការព្រមព្រៀងប្រកបកិច្ចល្អគប់គ្នាទៅ កុំដេកដំអក់ចាំទទួលយកសេចក្ដីសុខតែម្ដងនោះ មិនបានទេ ៗ

មួយទៀត ឧបាយនៃសេចក្ដីស្ងប់ដទៃ ក្រៅអំពី ទាន សីល ភាវនា មិនមាន គួរយើងធ្វើទាន ធ្វើសីល ធ្វើភាវនា ទើបបានស្ងប់ ៗ ហេតុអ្វី? ហេតុថា ទានជាគូប្រឆាំងនូវមច្ឆរិយៈ ១ មានលក្ខណៈហួងទុកនូវទ្រព្យរបស់ខ្លួន ៗ ទានមានលក្ខណៈចែកចាយទ្រព្យទំនុកបម្រុងខ្លួន ទាំងចែក

ចាយដល់អ្នកដទៃ ដោយប្រាថ្នាបូជាគុណ ឬអនុគ្រោះ ។ មច្ឆរិយៈជាកិលេសចោរមួយយ៉ាងអាក្រក់ បណ្ដាលឲ្យពុះក្ដៅ ឲ្យមានអធ្យាស្រ័យចង្អៀតដកពុំដល់ប្រៀតរកសេចក្ដីសុខខ្លួនឯងមិនបាន នាំឲ្យរក្សាតែទ្រព្យទុកដូចពស់ថ្លាន់រណ្ឌដំបូក ថែបានដូងនឹងអារក្សទឹករក្សាស្រះ មិនសម្រេចប្រយោជន៍ខ្លួននឹងអ្នកដទៃ មានតែសេចក្ដីពុះក្ដៅភ័យរន្ធត់ក្រែងទ្រព្យវិនាស នាំឲ្យបែកបាក់ចាកមិត្រ បង្កលោភឲ្យកាន់តែក្រាស់ឡើងៗ បើឃើញស្បមយាចក ញាតិ មិត្រ ក្រខ្សត់មកដល់ រមែងញ័ររន្ធត់ មិនអាចសំដែងទឹកមុខឲ្យស្រស់ញញឹមបាន ធ្វើឲ្យមានដំណើរចង្អៀត ដកបង្ក្រែកប្រៀតរកឧបាយសេចក្ដីសុខមិនកើត រវល់តែសំកុកចាំទ្រព្យដែលខ្លួនហួងទល់ស្លាប់ ។ មច្ឆរិយៈនេះមានក្រាស់ក្រួននៅក្នុងចិត្តបុគ្គលណា បុគ្គលនោះលោកហៅថា អសប្បុរស ទ្រព្យអសប្បុរសមិនសម្រេចប្រយោជន៍ដល់ជនដទៃ ព្រោះគ្មានមេត្តាប្រាថ្នាឲ្យអ្នកដទៃបានសុខទេ គិតឲ្យបានតែសុខខ្លួន ទោះបីប្រថុយចែកចាយទ្រព្យដល់អ្នកដទៃ គាល់តែឃើញកម្រៃវិលត្រឡប់មកវិញមួយជាពីរឡើងទៅ ដូចជនខ្លះគ្រាន់តែឲ្យចេកអំបូងតែមួយកំណាត់ត្អូញចង់បានសម្បត្តិសេដ្ឋី ។ យ៉ាងនេះតើ ទងបាត់ថាជាអ្នកមានអធ្យាស្រ័យស្ងប់ល្អដូចម្ដេចបាន ។ ហេតុហ្នឹង បានជាព្រះទ្រង់ញាណត្រាស់ទុកថា មច្ឆេរ ធនតោ មលំ សេចក្ដីកំណាញ់ជាមន្ទិលនៃអ្នកឲ្យ គឺជាស្ទះចិត្តស្ទះគំនិតឲ្យមានអធ្យាស្រ័យចង្អៀត ។

ឧបាយដែលនឹងផ្ចាញ់សេចក្ដីកំណាញ់ឲ្យខ្ចាត់ចេញបាននោះ ទាល់តែធ្វើទាន តាំងចិត្តផ្សាយមេត្តាករុណា ប្រាថ្នាឲ្យជាប្រយោជន៍ដល់ជនដទៃ ដោយបំណងបូជាគុណឬអនុគ្រោះ ហេតុនេះបានជាព្រះទ្រង់យសត្រាស់ប្រដៅទុកថា ជិនេ កទរិយំ ទានេន ត្រូវផ្ចាញ់សេចក្ដីកំណាញ់ដោយទាន ៗ ទានមានគុណជាអនេក គឺអាចកំចាត់សេចក្ដីកំណាញ់ ជាសឹកសត្រូវដល់ការស្ងប់ ធ្វើអធ្យាស្រ័យនឹងដំណើរឲ្យធំទូលាយល្អ ចងបាច់អ្នកដទៃដែលជាមិត្រស្រាប់ ឲ្យរឹងរឹតតែមានសេចក្ដីស្និទ្ធមេត្រីខ្លាំងឡើង ដែលមិនមែនជាមិត្រឲ្យជាមិត្រថែមឡើងទៀត ទើបព្រះបរមនាថត្រាស់ទុកថា ទទំ មិត្តានិ គន្ថតិ ចងអ្នកដទៃមកជាមិត្របានអាស្រ័យការឲ្យ គឺជាគ្រូឲ្យធម៌ ក៏ឲ្យធម៌ គ្រូឲ្យអាមិស ក៏ឲ្យអាមិស ៗ ទាន មានគុណសម្បត្តិឲ្យកើតស្ងប់ត្រជាក់ស្រួលក្នុងចិត្តខ្លួននឹងអ្នកដទៃជាដើមដូច្នេះ បានជាព្រះសាស្ដាត្រាស់ប្រដៅឲ្យធ្វើ មិនតែប៉ុណ្ណោះ ថែមទាំងរៀងទុកខាងដើមនៃបារមីធម៌ទាំង ១០ ផង ៗ ពួកយើងគួររំពឹងករកគុណនៃទានឲ្យឃើញជាក់លាក់ដោយខ្លួនឯង ៗ

ចំណែកខាងសីល ជាគូបង្ក្រាបនូវវីតិក្កមកិលេស គឺលោភ ក្រោធ វង្វេង ដ៏ក្រៀវក្រា ដែលអាចញ៉ាំងកាយនឹងវាចាឲ្យបៀតបៀនខ្លួននឹងអ្នកដទៃ គឺឲ្យប្រព្រឹត្តបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ នឹងក្រេបផឹកនូវសុរានឹងមេរ័យជាទីតាំងនៃសេចក្ដីប្រមាទ ដែលហៅថា បញ្ចវេរ (អំពើ

លាមក ៥ យ៉ាង) ។ បញ្ចវេរនេះ ជាអំពើថោកអាក្រក់ពន់ពេក បណ្ដាលឲ្យកើតមានភ័យរន្ធត់ក្ដៅក្រហាយដល់ខ្លួននិងជនដទៃ ហើយជាគ្រឿងគាស់បំផ្លាញឫសគល់របស់មនុស្សថែមទៀតផង នាំឲ្យបែកសាមគ្គីចងពៀរវេរដល់គ្នានឹងគ្នា មិនមែនមានគុណប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់បានឡើយ ព្រោះចំហាយភ្លើងគឺបញ្ចវេរនេះ ចេញមកអំពីភ្លើង ៣ គំនរ គឺភ្លើង រាគៈ ទោសៈ មោហៈ ដែលក្ដៅបំផុតរកភ្លើងអ្វីដូចគ្មាន មនុស្សអ្នកប្រកបបញ្ចវេរ រមែងបែរមុខទៅរកអបាយ ដែលមានសេចក្ដីក្ដៅក្រហាយចិត្តជាវិបាក ។ បុគ្គលឯណាស្វែងរកសេចក្ដីសុខខ្លួនដោយការប្រព្រឹត្តបញ្ចវេរ បុគ្គលនោះឥតបានសេចក្ដីសុខក្សេមឡើយ មានតែរងទុក្ខក្ដៅក្រហាយដរាប បើទុកជាមានសេចក្ដីពេញចិត្តប្រព្រឹត្តបញ្ចវេរដោយវង្វេងថាបានសុខ ក៏គង់ប្រែក្លាយជាទុក្ខធំវិញ ដូចលេបថ្នាំពិសលាយទឹកឃ្មុំ ឲ្យសុខស្រួលបានខ្លះ តែកន្លងរវាងលេបរួចហើយ ក៏នឹងក្លាយទៅជាទុក្ខលំបាកជាយ៉ាងពន្លឹកវិញ ។ ហេតុនេះហើយបានជាព្រះសាស្ដាត្រាស់ប្រដៅឲ្យលះមិនឲ្យប្រព្រឹត្តឡើយ ។ ការដែលលះបញ្ចវេរនេះបាន ត្រូវអាស្រ័យចំរើនសីល គឺប្រព្រឹត្តត្រឹមត្រូវមិនល្មើសមាត្រាច្បាប់ បានដល់សិក្ខាបទដែលព្រះសាស្ដាទ្រង់បញ្ញត្តហាមឃាត់ទុក ពោលដោយដាច់ខាត បានដល់សិក្ខាបទទាំង ៥ គឺ ការវៀរចាកសម្លាប់សត្វ ១ វៀរចាកកាន់

យកទ្រព្យដែលម្ចាស់ គេមិនបានឲ្យ ១ វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកនិយាយពាក្យមិនពិត ១ វៀរចាកហេតុជាទីតាំងនៃសេចក្តីធ្វេស គឺក្រេបផឹកគ្រឿងស្រវឹងគឺសុរានិងមេរ័យ ១ ។ ការលះវៀរចាកទាំង ៥ នេះ ហៅថានិច្ចសីល ជាសីលដែលត្រូវរក្សាជានិច្ច មិនត្រូវអាក់ខាន ។ និច្ចសីលមានគុណអាចកំចាត់នូវវីតិក្កមកិលេសដែលនាំឲ្យប្រព្រឹត្តបញ្ចវេរ ជាដើមផ្លូវសម្រាប់ឈានទៅរកគុណដ៏ខ្ពង់ខ្ពស់ ប្រៀបដូចដែនដីសម្រាប់បណ្តុះពូជដែលមានផលប្រយោជន៍ និងសង់លំនៅឲ្យបានល្អ និងនាំមកនូវសេចក្តីត្រជាក់ចិត្ត មិនក្តៅក្រហាយស្តាយក្រោយជាអានិសង្ស ។ ពួកជនអ្នកមានសីល អាស្រ័យនៅក្នុងទីណា សេចក្តីស្ងប់ដែលជាកំពូលនៃសេចក្តីសុខ រមែងកើតមានឡើងក្នុងទីនោះ ។ វិញ្ញូជន គួរពិចារណាឲ្យឃើញច្បាស់ដោយខ្លួនឯងចុះ ថាសីលនេះពិតជាទីពឹងរបស់ខ្លួននិងពួកជនដែលនៅរួមគ្នាជាប្រាកដ ព្រោះឧបទ្រពនិងទុក្ខភ័យទាំងឡាយ មិនដែលកើតមានអំពីពួកជនអ្នកមានសីលទេ ។ ហេតុនេះ បានជាព្រះមហាមុនីត្រាស់ឲ្យសាងសីល ដើម្បីធ្វើសេចក្តីស្ងប់ឲ្យកើតមាន ។

ចំណែកភាវនា ជាគួបក្រាបនូវកិលេសយ៉ាងកណ្តាលនិងកិលេសយ៉ាងល្អិត ។ កិលេសយ៉ាងកណ្តាល បានដល់នីវរណូបក្កិលេសទាំង ៥ មានកាមច្ឆន្ទៈ (សេចក្តីចូលចិត្តក្នុងកាម) ជាដើម ដែលហៅថា បរិយុដ្ឋាន-

កិលេស សម្រាប់ចំពាស់ចិត្តឲ្យខូចបាក់សេចក្តីស្ងប់ ញ៉ាំងសេចក្តីទុក្ខឆេះឆួលពុះក្តៅឲ្យកើតឡើងក្នុងចិត្ត ធ្វើចិត្តឲ្យមានទុក្ខទោសពោរសាប់សល់ខ្វល់ខ្វក់វិនាសបាក់សេចក្តីសុខ ។

កិច្ចដែលនឹងកំចាត់បង់នូវកិលេសនេះ ត្រូវប្រើសមថភាវនារកឧបាយធ្វើចិត្តឲ្យស្ងប់ជាសមាធិ ដោយណោងយកអារម្មណ៍ដែលជាគូទំនាស់នឹងកិលេសនោះ ដូចពួកយើងដែលធ្លាប់នាំគ្នាធ្វើកិច្ចថ្វាយបង្គំព្រះនឹករំពឹងដល់គុណព្រះរតនត្រ័យ នឹងនឹករំពឹងមើលនូវគុណសេចក្តីល្អដែលមាននៅក្នុងខ្លួនជាដើម ៗ នេះហើយ ដែលជាឧបាយសាងសេចក្តីស្ងប់ធ្វើចិត្តឲ្យស្រួល ធ្វើចិត្តឲ្យរងថ្លាមានពន្លឺមិនកករល្អក់ ។

កិលេសយ៉ាងល្អិត បានដល់អនុស័យកិលេសទាំង ៧ មានកាមរាគៈ (គ្រឿងជ្រលក់ចិត្តជាប់ក្នុងកាម) ជាដើម ជាកិលេសមួយពួកសម្ងំស្ងៀមនៅក្នុងសន្តានចិត្ត ដូចអាសិរពិសដែលពួនសម្ងំលាក់ខ្លួនក្នុងដំបូក មិនទាន់ចេញស្វែងរកអាហារ ដកពពាព្រួសពិសសំដែងឫទ្ធិឲ្យប្រាកដ កិលេសនេះក៏ដូចគ្នា តែងសម្ងំនៅក្នុងដំបូកគឺមហាភូតទាំង ៤ ដែលមានទ្វារ ៦ គឺអាយតនៈ លុះត្រូវអារម្មណ៍ប៉ះពាល់គ្រាណា ទើបចេញសំដែងឫទ្ធិព្រួសពិសឲ្យប្រាកដ នាំឲ្យក្រហល់ក្រហាយក្នុងចិត្ត នាំឲ្យបៀតបៀនខ្លួននឹងអ្នកដទៃ ។

កិច្ចដែលលះកិលេសអម្បាលនេះ ត្រូវអាស្រ័យវិបស្សនាការនោះ ជាគ្រឿងបង្ក្រាបន្ទូរកិលេសនេះ គឺត្រូវចំរើនប្រាជ្ញាពិចារណាកងសង្ខារឲ្យឃើញច្បាស់តាមយថាភូត គឺជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ដើម្បីធ្វើចិត្តឲ្យដាច់អាល័យអំពីកងសង្ខារ ដែលធ្លាក់នៅក្នុងអំណាចទុក្ខសច្ចធាតុ ហើយធ្វើចិត្តឲ្យស៊ប់ចាំក្នុងវិសង្ខារ គឺព្រះនិព្វានដែលផុតចាកបំណោមនៃទុក្ខសច្ចធាតុ ដរាបដល់សម្លាប់អនុសយកិលេសនេះអស់ឥតមានសេសសល់ ធ្វើកាយឲ្យបរិសុទ្ធស្អាតបាតចាកកិលេស ដូចជាដំបូកដែលស្អាតមិនមានគ្រឿងសៅហ្មងសព្វនៅខាងក្នុង ។ ការផ្ចាញ់កិលេសទាំង ៣ ជាន់ត្រូវអាស្រ័យសីល សមាធិ បញ្ញា ដូចពណ៌នាមកនេះ សមនឹងព្រះបាលីថា សីលេន វីតិក្កមំ បរិយុដ្ឋំ សមាធិនា បញ្ញាយ អនុសយំ ជិន្ទំ ឥត្ថា ជិញ្ញានមុត្តំ កាលបើបុគ្គលផ្ដាច់បង់វីតិក្កមកិលេសដោយសីល បរិយុដ្ឋានកិលេសដោយសមាធិ អនុសយកិលេសដោយបញ្ញា រមែងបានទូវព្រះនិព្វានដ៏ខ្ពង់ខ្ពស់ ។

សំដែងមកក្នុងសន្តិកថា ពណ៌នាអំពីគុណនៃសេចក្ដីស្ងប់ និងឧបាយដែលជាផ្លូវនៃសេចក្ដីស្ងប់ ឯរាំ ក៏បប់ល្មមសមគួរដោយទូវប្រការ ៗ

ឥមិនា ធម្មទានេន សុវត្ថិ ហោតុ សព្វទា ដោយគុណានុភាពនៃធម្មទាននេះ សូមសួស្ដីជយមង្គលសំរេចដល់ពួកយើងដែលជាពុទ្ធសាសនិកៈគ្រប់ៗកាលតទៅហោង ៗ

ចប់វិទ្យុធម្មទេសនា កណ្ឌទី ៦ តែប៉ុណ្ណេះ ។

## អំពីកាលិទាសៈ

### និងកិច្ចការជាថ្វីដៃរបស់លោក

កាលិទាសៈនេះ ជាឈ្មោះចិន្តកវីម្នាក់នៅប្រទេសឥណ្ឌា កាលពីសម័យពុទ្ធសករាជ ៩៤៣ លោកចិន្តកវីនេះមានកេរ្តិ៍ឈ្មោះល្បីល្បាញណាស់ក្នុងប្រទេសឥណ្ឌាសម័យបុរាណ ។ ឯរឿងរ៉ាវជាថ្វីដៃរបស់លោក គេបានប្រែចេញពីភាសាសំស្ក្រឹតមកជាភាសាផ្សេងៗក្នុងប្រទេសឥណ្ឌានិងក្នុងទ្វីបឧរុប ដ្បិតរឿងរ៉ាវអស់នោះ មិនមែនប្រើការបានគ្រប់គ្រាន់ត្រឹមតែជាភាសាកាព្យប៉ុណ្ណោះទេ គេអាចយកទៅប្រើលេងល្ខោនបានទៀតផង សឹងជាទីចាប់ចិត្តគំនិតរបស់ពួកអ្នកមើលល្ខោនទូទៅ ។ លោកអ្នកប្រាជ្ញនេះហើយ ដែលយល់ច្បាស់នូវអាការៈនៃចិត្តគំនិតមនុស្ស ហើយអាចយឹតយោងចិត្តអ្នកមើលឲ្យជាប់ចិត្តនឹងរឿងរ៉ាវរបស់លោក ។

ក្នុងចំណោមរឿងរ៉ាវដែលល្បីល្បាញនោះ គួរស្រង់យករឿងមួយមកពោល ដែលហៅថា ឫតុសំហារៈ ជារឿងអនុលោមទៅតាមរដូវកាលជារឿងដែលលោកអ្នកប្រាជ្ញនេះចង្អុលបង្ហាញឲ្យឃើញចិត្តគំនិតរបស់មនុស្សយើងដែលជាប់ទាក់ទងនឹងធម្មជាតិ ហើយតែងប្រែប្រួលទៅតាមរដូវកាល ទើបរឿងរបស់លោកពីរោះចាប់ចិត្តគ្រប់ៗរដូវរៀងមក ។

ក្នុងរដូវក្តៅ ទុកជាក្តៅស្ទើរឆេះក្នុងវេលាថ្ងៃ តែដល់វេលាយប់អាកាសប្រែត្រជាក់ជាមួយនឹងផ្ទៃផែនដី ទើបនាំឲ្យចិត្តគំនិតរីករាយឡើងវិញ

នៅឱកាសនោះ ព្រះចន្ទធ្លុះពន្លឺស្ទើរត្រជាក់មកកាន់ផ្ទៃផែនដីនេះ រឿងនេះមានទំនងដូចជាចិត្តរបស់មនុស្សយើង ដែលពុះក្តៅហើយគេអាចបន្ធូរបង់សេចក្តីក្រហល់ក្រហាយចេញទៅបានដោយសេចក្តីមេត្រីស្នេហា ។ សេចក្តីស្នេហានេះ អាចកើតឡើងបានដោយត្រូវខ្យល់បក់ឲ្យរហើយយ៉ាងរំភើយៗ ឯព្រះចន្ទរះឡើងក្នុងវេលាយប់ បែរមុខមើលមកគូស្នេហា ដែលនៅក្រោមពន្លឺដួងចន្ទ ទ្រង់សំឡឹងមើលដោយអាការៈញាសនឹងស្នេហា ។ ពួកនាគក៏ធុរនេះឡើងដោយកំដៅថ្ងៃ ហើយលូនទៅក្នុងលូលិទាល់តែចេះផ្លូវ សត្វក្របីងើយបែមុខដកដង្ហើមឡើងធំស្ងើតហើយលៀនអណ្តាតធ្លាក់ស្តោកដើរត្រាច់ផ្តាក់ពេរកទឹក ។

សៀនដូរចូលមក ហាក់ដូចជាក្បួនហោរបស់ព្រះរាជានៅក្នុងចំណោមកន្ទែតដែលមានការុងច្រូងប្រាង, ផ្កាឈានទុកជាស្គរ ហើយពពកក៏ក្រាស់ទៅដោយទឹកភ្លៀងទុកដូចជាដំរី ឥន្ទធនូនឹងភ្លាកទុកដូចជាផ្លេកបន្ទោរ ហើយផែនដីទុកដូចជាស្តីច្រដាប់តាក់តែងដោយគ្រឿងមាសពេជ្រដ៏រុងរឿងគឺស្មៅខ្ចី ក្មេកកាយកន្ទុយទុកដូចជាបាច់ផ្កា ។ ពួកស្រីតែងមានសេចក្តីស្នេហា នៅក្នុងដៃសហាយរបស់នាងៗ ក្មេចខ្លាចស្វាសេពន្ទះ ៗ ខណៈនោះមើលឃើញមេឃឃើញដីទាំងអស់ឥតកំបាំង ទឹកទន្លេតែងហូរទៅ, ខ្យល់ព្យុះតែងយល់សព្ទូ, ភ្លៀងតែងធ្លាក់ចុះមក,

ក្ងោកក៏ពង់កាំរំភាយកន្ទុយ, ដំរីក៏ស្រែកកងរំពង, ប្រពន្ធដែលលែងប្ដីទៅតែងយល់សប្ដិអាក្រក់ ពពកចុះមកទាបច្រើនហើយធ្ងន់ដោយទឹកភ្លៀង... ។

រដូវដើមឈើជ្រុះសន្លឹកចូលមក ទុកដូចជាថ្ងៃអាពាហ៍ពិពាហ៍ផ្កាឈូកដែលក្រពុំរីកឡើង; វេលាយប់តែងតែប្រាសចាកពពកដែលអណ្ដែតទៅបាំងពីមុខដួងចន្ទ្រ; ខ្យល់បក់ផាត់ដើមស្វាយកំពុងផ្កា; ប្រឡាយទឹកតែងបែកទឹកខ្វាត់ខ្វាយ; ផែនដីក៏ប្រកបដោយសេចក្ដីរីករាយ; ទេពធីតាឈ្មោះស្រីបានផ្សាយសេចក្ដីសុខទឹងលំអចុះមក ។

ដល់រដូវត្រជាក់ គូស្នេហាតែងបិទបង្អួចហើយបានសេចក្ដីកក់ក្ដៅដោយស្មោះនៃដួងអាទិត្យ; ឯផ្ទៃផែនដីដេរដាសដោយស្រូវចំរូត; បុរសស្នេ-ហាតែងឱបក្រសោបស្ដ្រីជាទីស្នេហារបស់ខ្លួន ។

ដល់រដូវទឹកសន្សើមធ្លាក់ ជាពេលប្រកបដោយសេចក្ដីស្នេហា; ស្រីៗតែងសៀតបងផ្កានៅលើសក់របស់ខ្លួន ។ រដូវនេះហើយដែលប្រកបដោយសេចក្ដីស្នេហា; សេចក្ដីរីករាយ ។

ដល់រដូវដើមឈើលាស់សន្លឹក ជារដូវដែលសេចក្ដីស្នេហា ឬព្រះកាមទេពទ្រង់ដំឡើងសរកាម ត្រៀមបាញ់ទម្លុះបេះដូងក្រមុំកំលោះ ។ វត្ថុទាំងអស់សុទ្ធតែតាក់តែងឲ្យល្អឡើង ទឹកមានពណ៌ខៀវក៏ដេរដាសដោយផ្កាឈូក ហើយដើមព្រឹក្សក៏ទោរទន់ចុះទៅដោយទម្ងន់ផ្កា ។ នេះហើយជាខែមធុរស សូរមេឃយំទ្រហឹង; ពួកបក្សាបក្សីក៏យំឮសូរសោន;

កូនក្ដាំទាំងឡាយក៏ដើរជាសដោយផ្កា; ខ្យល់បក់រំភើយៗនាំក្លិនក្រអូបនៃផ្កាស្វាយសាយចេញទៅ; វេលាយប់ក៏សប្បាយពន់ពេក ពន្លឺដួងចន្ទ្រក៏ភ្លឺថ្លាត្រចះ ៗ មេឃទូតឬពពកនាំសារ ហាក់ដូចជាដំណាលពង្សាវតារនិយាយពីយក្ស ១ ដែលត្រូវទោសនិរទេស ហើយបានផ្ញើសារមួយតាមពពកទៅដល់ភរិយាខ្លួន ដ្បិតខ្លួននៅឆ្ងាយដាច់ស្រយាលពីភរិយា យក្សនោះក៏ពន្យល់ផ្លូវប្រាប់ពពកតាមដំណើរសព្វគ្រប់ ៗ កាលពពកធ្វើដំណើរមកដល់ខាងមុខភ្នំហិម៉ាល័យ ក៏ក្រឡេកទៅឃើញក្រុងយក្ស ពពកក៏ស្គាល់ច្បាស់ជាផ្ទះយក្ស នៅជិតស្រះមួយដ៏ដេរដាសដោយផ្កាឈូកមាស ហើយមានភ្នំមួយដែលមានកំពូលសុទ្ធតែជាពេជ្រនិលចិន្ដា មុននឹងបញ្ចប់សារយក្សនោះពោលថា "ឱ! ពពកអើយ អ្នកនេះហើយដែលជាបក្ខពួកនៅក្នុងផ្លូវវៀង សូមឲ្យអ្នកកុំបីព្រាត់ប្រាសឃ្លាតឃ្លាពីផ្លេកបន្ទោរដែលជាប្រពន្ធដ៏ជាទីស្នេហារបស់អ្នកឡើយ ៗ

*

* *

រឿងឝកុន្តលា ក៏ជាថ្វីដៃដ៏ចំណាប់ ១ របស់ចិន្តកវីកាលីទាសៈនេះដែរ ហើយគេបានប្រែមកជាពាក្យកាព្យដែរ បណ្ដាអ្នកដែលបានមើលសេចក្ដីប្រែជាពាក្យកាព្យនោះ ក៏មានសេចក្ដីសរសើរទាំងអស់ ដូចមានមហាកវីរបស់អឺរ៉ុបម្នាក់មានអាយុ ៨០ ឆ្នាំហើយ លុះលោកបានមើលសេចក្ដីប្រែ

ជាភាសារបស់លោកចប់ហើយក៏លុតជង្គង់ចុះពោលថា "ខ្ញុំសូមអរគុណព្រះដ៏ជាម្ចាស់សួគ៌ ដែលទ្រង់ប្រទានឲ្យខ្ញុំមានជីវិតរស់នៅរហូតដល់សព្វថ្ងៃនេះ" ហើយលោកតែងជាពាក្យកាព្យមួយដូចមានសេចក្ដីខាងក្រោមនេះ:

"វត្ថុទាំងអស់ ពោះមេឃក្ដី ដីក្ដី ផ្កាឈើនៅរដូវលាស់សន្លឹកក្ដី ផ្លែឈើនៅរដូវដម្រុះស្លឹកក្ដី សុទ្ធតែធ្វើឲ្យអ្នកសប្បាយចិត្ត ឲ្យអ្នកបានបរិភោគ ឲ្យអ្នកឆ្អែត ហើយធ្វើឲ្យមានលំអផង តែបើអ្នករពុកដល់ឲ្យស្រេបព្រមគ្នាតែម្ដងនោះ មានតែពាក្យ ១ ម៉ាត់ទេដែលហៅថា "គក្កុន្ទលា ឈ្មោះនេះហើយ ទឹងប្រាប់អ្នកឲ្យយល់សព្វគ្រប់ទាំងអស់" ។

លោកចិន្តកវីកាលីទាសៈ ដែលបានតែងពាក្យកាព្យនេះលោកបានចាប់យកដំណើរទំនងជាទចាស់ តាមដែលមានក្នុងរឿងមហាភារតៈ ។ ឯរឿងរ៉ាវនោះដូច្នេះ:

លោកមហាឥសីមួយរូបឈ្មោះកាមទេវៈ បានសាងអាស្រមបទនៅនាកណ្ដាលព្រៃ ជាទីសំណាក់នៅជាមួយនឹងភរិយាឈ្មោះនាងគោតមី ហើយនឹងពួកឥសីក្មេងៗ សុទ្ធតែស្លៀកសំបកឈើទាំងអស់ ។ ឥសីកាមទេវៈនឹងនាងគោតមីមានសេចក្ដីព្រួយចិត្តណាស់ ដ្បិតគ្មានកូនមួយសោះៗ

មានថ្ងៃមួយនោះមាននាងទារិកាតូចម្នាក់មកកើតនាទីព្រៃនោះ ម្ដាយជាទេពតាឈ្មោះនាងមេនកា មកប្រសូតកូនស្រី ១ ចោលក្នុងព្រៃនោះ ។

អស់សត្វបក្សាបក្សីមកហោមរោមការពារអន្តរាយនាងទារិកានោះ ៗ ដល់ព្រឹកឡើង ពួកឥសីក្មេងៗ នាំគ្នាមករើសបេះផ្លែឈើ ក៏បានឃើញនាងទារិកាគកុន្តលា ហើយយកទៅថ្វាយឥសីជាគ្រូ ៗ នាងគកុន្តលាបានធាត់ធំចំរើនឡើងក្នុងអាស្រមបទ ហើយនាងមានស្រីកំលៀង ២ នាក់ ឈ្មោះអនសូយៈ ១ ប្រិយម្ពទៈ ១ នឹងកូនម្រឹគមួយ តែងដើរតាមនាងទៅគ្រប់ៗអន្លើ ៗ ស្ត្រីសំឡាញ់ទាំង ៣ នាក់នាំគ្នាជួយរក្សាសំអាតអាស្រម នាងទាំង ៣ តែងលេងសើចរីករាយកំសាន្តចិត្តជាមួយគ្នាជាដរាប ៗ

ក្នុងថ្ងៃមួយនោះ ស្តេចទុស្សន្តៈជាមហាក្សត្រមានឫទ្ធានុភាពមួយ ឯអាស្រមបទរបស់ឥសីកាមទេវៈក៏នៅក្នុងអាណាចក្រទ្រង់នេះដែរ ថ្ងៃមួយស្តេចចេញទៅបរបាញ់នឹងក្តុកហ្លួងម្នាក់ឈ្មោះមទវ្យៈ ៗ សូរត្រែរបស់ស្តេចលាន់ឮកងរំពងទៅទាំងព្រៃ ស្តេចគង់លើរាជរថមាសដេញបាញ់ក្តាន់មួយចូលទៅក្នុងព្រៃជ្រៅហូតមកដល់អាស្រមរបស់ឥសី ៗ ស្តេចក៏លែងដេញបាញ់សត្វនោះ ហើយយាងចុះទៅកាន់បណ្ណសាលា ស្រាប់តែទ្រង់ទតឃើញនាងគកុន្តលា ៗ តាំងពីពេលនោះមក ទ្រង់មិនព្រមចេញពីអាស្រមបទ ហើយទ្រង់មិនព្រមត្រឡប់ទៅព្រះនគរវិញផង ៗ

នៅថ្ងៃមួយនោះ ស្តេចនឹងនាងគកុន្តលាទ្រង់កម្រងផ្កាអាពាហ៍ពិ-ពាហ៍ជាមួយគ្នា ៗ តមកក្នុងថ្ងៃមួយ ស្តេចទ្រង់ឡើងគង់រាជរថមាសត្រឡប់ចូលទៅកាន់ព្រះរាជវាំងវិញ ឯនាងគកុន្តលាក៏ត្រឡប់ទៅកាន់អាស្រម

ដែរ ប៉ុន្តែមុនស្តេចយាងត្រឡប់ទៅកាន់ព្រះរាជវាំងនោះ ទ្រង់បានប្រទានព្រះទំរង់១វង់ទៅនាងឝកុន្តលា ហើយទ្រង់សញ្ញាថានឹងមកទទួលនាង ៗ តែគមក ស្តេចមិនបានត្រឡប់ទៅវិញឡើយ ៗ ឯនាងឝកុន្តលាក៏សោយសោកទន្ទឹះខ្សឹកខ្សួលនៅតែក្នុងអាស្រមមិនបានសង្កេតគន់មើល មហាឥសីទូវិសៈ ចូលមកក្នុងអាស្រម ហើយខឹងនឹងនាងជាខ្លាំង ទើបដាក់បណ្តាសានាងថា កុំឲ្យស្តេចនោះចាំនាងបានឡើយ ៗ ឯស្រីសំឡាញ់ទាំងពីរបានឮមហាឥសីដាក់បណ្តាសាដូច្នោះក៏ភិតភ័យ ទើបនាំគ្នាអង្វរសូមឲ្យមហាឥសីដកពាក្យបណ្តាសានុ៎ះចេញ ទើបមហាឥសីកែបន្ទូរថា បើស្តេចបានឃើញព្រះទំរង់ដែលពាក់នៅនឹងដៃនាង សូមឲ្យស្គាល់ថាជានាងឝកុន្តលា ៗ ក្នុងសម័យនោះ ស្តេចគង់ក្នុងព្រះរាជវាំង ទ្រង់ភ្លេចភ្លាំងអាស្រមបទនឹងនាងឝកុន្តលាសូន្យឈឹង (ដោយត្រូវបណ្តាសាឥសី) ៗ

ឯកាមទេវៈក៏ទូន្មាននាងឝកុន្តលា អំពីច្បាប់ដែលនាងទៅនៅនឹងព្រះរាជស្វាមី ៗ ឯស្រីសំឡាញ់ទាំងពីរនាក់ក៏គាត់តែងរៀបចំខ្លួនប្រាណឲ្យនាងទើបនាំនាងចេញដំណើរទៅ លុះនាំគ្នាដើរទៅបានពាក់កណ្តាលផ្លូវនាងក៏ចុះទៅងូតទឹកក្នុងគង្គាមិនបានប្រយ័ត្ន ចិញ្ចៀនដែលពាក់នឹងម្រាមដៃក៏របូតជ្រុះទៅក្នុងស្ទឹងទៅ ៗ លុះនាងដល់ទៅព្រះរាជវាំង ស្តេចក៏ឥតស្គាល់នាងបន្តិចទើបទ្រង់ដណ្តឹងសួរ ៗ នាងឝកុន្តលាទូលរៀបរាប់កាលទ្រង់ទៅសំណាក់នៅក្នុងអាស្រមសាលា ហើយទ្រង់ប្រទានចិញ្ចៀន

១ ឲ្យនាង តែមហាក្សត្រទ្រង់នឹកមិនឃើញសោះ ឯនាងឝកុន្តលាក៏ទ្រង់ព្រះកន្សែងសោកជាខ្លាំង ទើបនាងទេពធីតាឈ្មោះមេនកាដែលជាម្ដាយនាង បានឮសូរសព្ទសោការបស់កូនក៏ចុះពីស្ថានសួគ៌មក ហើយនាំនាងឝកុន្តលាទៅកាន់អាស្រមរបស់ឥសីកស្សបៈ នៅទីនោះនាងឝកុន្តលាប្រសូតបានកូនប្រុសមួយ ហើយជួយប្រឡោមលោមចិត្តនាងឲ្យបន្ធូបង់សេចក្ដីទុក្ខព្រួយបានខ្លះ ៗ

គង់សម័យថ្ងៃមួយនោះ មានអ្នកនេសាទត្រីម្នាក់ទៅបង់សំណាញ់នៅទាក់ស្ទូងបានត្រី ១ ធំ ហើយយកមកវះពោះចេញ ក៏ស្រាប់តែឃើញព្រះទំរង់ស្ដេចនៅក្នុងក្រពះត្រីនោះ ដែលរបូតពីដៃនាងឝកុន្តលាពេលចុះទៅងូតទឹក ហើយត្រីនោះលេបបាត់ទៅ ៗ ឯអ្នកនេសាទក៏យកចិញ្ចៀននោះទៅលក់ឲ្យផ្ទះជាងទង ឯជាងទងឃើញក៏ស្គាល់ជាចិញ្ចៀនរបស់ស្ដេច ព្រោះមានព្រះសញ្ញាស្ដេចប្រថាប់នៅនឹងក្បាលចិញ្ចៀន ទើបនាំអ្នកនេសាទនោះទៅកាន់ព្រះរាជវាំង ហើយក្រាបទូលរៀបរាប់ពីដំណើរដែលខ្លួនរើសបានចិញ្ចៀននេះ ៗ ឯព្រះមហាក្សត្រកាលទ្រង់ទតឃើញព្រះទំរង់នេះ ក៏ទ្រង់នឹកឃើញនាងឝកុន្តលាមួយរំពេច ទើបទ្រង់ឲ្យដើររកនាងសព្វអន្លើ (តែមិនប្រទះ) លុះទ្រង់ត្រេកត្រចូលទៅក្នុងព្រៃធំ ទើបទ្រង់ទតឃើញព្រះរាជបុត្រកំពុងលេងកំសាន្តជាមួយនឹងកូនរាជសីហ៍ តែទ្រង់ឥតស្គាល់ជាព្រះរាជបុត្រទេ ហើយទ្រង់យកព្រះហស្តឱបកុមារ

នោះ ៗ ទើបនាងឝកុន្តលាចូលទៅជិតទ្រង់ ព្រះមហាក្សត្រក៏ស្គាល់ព្រះនាងជាក់ច្បាស់ ៗ ឯពាក្យបណ្ដាសារបស់ឥសីទុរ្វាសៈក៏សាបរលាបអស់ទៅ ទើបមហាក្សត្រនាំនាងឝកុន្តលា នឹងព្រះរាជបុត្រត្រឡប់ចូលទៅក្នុងព្រះនគរវិញ ហើយក៏មានសេចក្ដីសុខក្សេមក្សាន្តជាមួយគ្នាតរៀងទៅ ៗ

*

* *

មានកំណាព្យមួយទៀត ជាកំណាព្យល្បីល្បាញណាស់ដែរ ជារបស់លោកកាលិទាសៈ ហៅថា រឃុវង្សៈ ប្រែថា វង្សព្រះអាទិត្យ ៗ រឿងនេះជាថ្វីដៃដ៏ថ្លៃថ្លាមួយ ដែលគេទុកជាគំរូបែបផែនក្នុងការតែងសេចក្ដី ៗ លោកបន្តកវីបានពោលអំពីការធំៗរបស់ពួកនរសព្រះអាទិត្យដែលហៅថា ឥក្សាកុ មានក្សត្ររឃុជាបឋមវង្ស ហើយមានព្រះរាមដែលជាក្សត្រ ១ អង្គមានកេរ្តិ៍ឈ្មោះល្បីល្បាញបំផុត ៗ មានទំនុកកាព្យ ៩ ទំនុកដំបូងនោះ សុទ្ធតែពោលអំពីបុព្វបុរសរបស់ព្រះរាម ហើយទំនុកកាព្យឯទៀតពោលពីព្រះរាមនឹងព្រះរាជវង្សព្រះរាមតៗមក ៗ ទំនុកអស់នេះទុកដូចជាសេចក្ដីសង្ខេបមួយក្នុងរឿងរាមាយនៈ ៗ

*

* *

ក្នុងរឿងកុមារសម្ភវៈ ឬកំណើតរបស់កុមារនោះ លោកកាលីទាសៈ សរសេររំឭកដល់កាត់គេយៈ ជាព្រះប៉ែកខាងចម្បាំង ជាបុត្រព្រះសិវៈ ។ ក្រៅពីនេះ “ឫតិៈឆ្ពោះនៃសេចក្ដីពាហាន” ក៏ជាស្នាដៃរបស់លោកកាលីទាសៈដែរ ឃើញមានរឿងការទៅក្នុងទំនុក ១ ក្នុងឫគវេទៈ ។ លោកកាលីទាសៈ ដំណាលអំពីសេចក្ដីស្នេហារបស់ទេពធីតាឧរ្វសីនិងខ្មោច ១ ហើយពោលអំពីសេចក្ដីលំបាកនៃគូស្នេហា ក្នុងកាលដែលទេពធីតាស្ងួនរកខ្មោចនោះ ។ ប៉ុន្តែព្រះឥន្ទ្រអនុញ្ញាតឲ្យខ្មោចនោះថែរក្សាទេពធីតាឧរ្វសីនៅក្បែរខ្លួន ។

*

* *

មាលវិកាគ្និមិត្រៈក៏ជាពាក្យកាព្យមួយ និយាយពីសេចក្ដីស្នេហា ដែលលោកកាលីទាសៈដំណាលពីសេចក្ដីស្នេហារបស់ស្ដេចអគ្និមិត្រៈ ។ ស្ដេចនេះលុះអំណាចស្នេហានឹងស្រីបម្រើម្នាក់ របស់ព្រះអគ្គមហេសី មាលវិកាអគ្គមហេសីទី ១ ខំទប់ទល់តាំងពីដំបូងមិនឲ្យស្រីបំរើមករួមជា-មួយនឹងស្ដេច ។ នាងឥតរាក់ទាក់ នាងមិនព្រមឲ្យស្ដេចឡើងជួបនោះដែរ ហើយនាងទឹងប្រចណ្ឌជាខ្លាំង តែតមកនាងបែរតែងអត់ទ្រាំទៅ ទើបនាងបំរើមាលវិកាបានជាព្រះជាយា ១ របស់ស្ដេចនោះ ។

# ប្រវត្តិពួកឧបាសិកា

១ សុជាតា- សេដ្ឋិធីតា- ជាបុត្រីរបស់សេដ្ឋិយកុដុម្ពិក៍ កើតនៅតំបន់សេនានិគម ដែនឧរុវេលប្រទេស លុះបានចំរើនវ័យឡើងហើយ បានទៅកាន់ដើមជ្រៃធំមួយដើម តាំងសេចក្តីប្រាថ្នាថា បើខ្ញុំបានស្វាមីដែលមានជាតិត្រកូលស្មើគ្នា ហើយបានកូនប្រុសដំបូង ខ្ញុំនឹងមកធ្វើការបួងសួងលោកពល ១ ឆ្នាំ ១

លុះចំណេរកាលតមកនាងក៏បានសម្រេចសមតាមប្រាថ្នាគ្រប់ប្រការ ហើយចួនជាព្រះសិទ្ធត្ថរាជកុមារ ធ្វើទុក្ករកិរិយាកន្លងមក ៦ ឆ្នាំហើយ ដល់ថ្ងៃវិសាខបុណ្ណមីក៏បានសម្រេចព្រះពោធិញ្ញាណ ស្តេចមកគង់នៅក្រោមដើមឈើនោះ ។ ឯនាងសុជាតា បានក្រោកឡើងអំពីព្រឹក មានបំណងនឹងទៅធ្វើពិធីបួងសួងទេវតា ហើយបានចាត់ចែងរកយកទឹកដោះពីមេគោ ក៏រកបានដោយងាយស្រួល ក្នុងវេលានោះ កូនគោទាំងឡាយមិនបានបៅដោះមេគោឡើយ គ្រាន់តែយកភាជន៍ទៅរងពីក្រោមដោះ ទឹកដោះក៏ហូរចេញមកឯង ៗ នាងយកទឹកដោះនោះទៅដាំធ្វើជាមធុបាយាស លុះរួចស្រេចហើយក៏នាំយកទៅឯដើមជ្រៃធំនោះ ដើម្បីនឹងធ្វើពិធីបួងសួងលាបំណន់ដែលខ្លួនបានបន់ទុកនោះ ។ ថ្ងៃនោះ ព្រះពោធិសត្វស្តេចត្រេចទៅបិណ្ឌបាតត្រឡប់មកពីព្រឹកហើយគង់នៅក្រោមដើមជ្រៃនោះ នាងសុជាតាមកជួបសំគាល់ថាជាទេវតា ក៏

នាំមធុបាយាសទៅថ្វាយ ទមស្សការហើយពោលពាក្យថា សេចក្តីប្រាថ្នារបស់ខ្ញុំម្ចាស់បានសម្រេចយ៉ាងណា ក៏សូមឲ្យសេចក្តីប្រាថ្នារបស់លោកម្ចាស់បានសម្រេចយ៉ាងនោះចុះ ។

ឯព្រះបរមពោធិសត្វទ្រង់ទទួលបាយមធុបាយាសហើយ ស្តេចយាងទៅកាន់មាត់ព្រាំងស្ទឹងនេរញ្ជរា ទ្រង់ដាក់ថាសមាសទង៏មាត់ព្រាំង រួចស្តេចចុះស្រង់ក្នុងគង្គាជម្រះព្រះកាយរួចស្រេចហើយស្តេចឡើង ទ្រង់ពូតបាយមធុបាយាសបាន ៤៩ ដុំ លុះសោយស្រេចស្តេចបណ្តែតថាសមាសទៅក្នុងស្ទឹង ស្តេចវិលមកកាន់ពោធិមណ្ឌល ក្រោមដើមមហាពោធិព្រឹក្សវិញ ហើយទ្រង់ចំរើនធម៌បានសម្រេចអនុត្តរសម្មាសម្ពោធិញាណ ស្តេចប្រថាប់នៅទីនេះជាវេលា ៧ សប្តាហ៍ ។ តអំពីនោះស្តេចទៅសំដែងព្រះធម្មចក្រនៅព្រៃឥសិបតនម្រឹគទាយវ័ន ទ្រង់ទតឃើញឧបនិស្ស័យរបស់យសកុលបុត្រ ជាបុត្រនាងសុជាតា ទើបស្តេចទៅប្រថាប់ក្បែរគល់ឈើមួយដើម ។ ឯយសកុលបុត្រមានចិត្តនឿយណាយ ក្នុងការគ្រងឃរាវាស ទើបចេញពីគេហស្ថានទៅ ស្រាប់តែបានជួបប្រទះនឹងព្រះបរមសាស្តានៅទីនោះ បានស្តាប់ព្រះធម្មទេសនាហើយ បានសម្រេចមគ្គផលដល់ថ្នាក់អនាគាមី ។ ឯបិតារបស់យសកុលបុត្រទៅតាមជួបនឹងព្រះបរមសាស្តា បានស្តាប់ព្រះធម្មទេសនាសម្រេចសោតាបត្តិផល

យសកុលបុត្របានសម្រេចព្រះអរហត្តផល ព្រះអង្គទ្រង់អនុញ្ញាតឲ្យបួស ដោយវិធី "ឯហិភិក្ខុឧបសម្បទា" ។ ឯបិតារបស់ព្រះយស បានទូលនិមន្តព្រះបរមសាស្តាឲ្យស្តេចទទួលបិណ្ឌបាតឯផ្ទះរបស់ខ្លួន ។ សម្តេចព្រះបរមសាស្តាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់សំដែងព្រះធម្មទេសនា វេលាចប់ទេសនា នាងសុជាតាជាមាតាព្រមទាំងភរិយារបស់ព្រះយស បានសម្រេចសោតាបត្តិផលទាំងពីរនាក់ ។ នាងសុជាតានឹងកូនប្រសាបានតាំងនៅក្នុងតេវាចិកសរណគមន៍ជាដំបូងក្នុងថ្ងៃនោះ អាស្រ័យហេតុនេះ ទើបព្រះសាស្តាទ្រង់តាំងក្នុងឯតទគ្គៈ ប្រសើរលើសលែងពួកឧបាសិកា ដែលបានដល់សរណៈមុនឧបាសិកាទាំងពួង ។

ចប់ប្រវត្តិសង្ខេបរបស់ នាងសុជាតា-សេនីយធីតា តែប៉ុណ្ណោះ ។

# លោកនេយ្យ ពាក្យកាព្យ

(តមក)

អស់ទេពស្ងួតស្ងំ ទឹងបកមុខ ទឹងអ្នកពាលា នៅនាលោកិយ
អប្រិយយសា លុះដល់មរណា សោយទុក្ខធ្ងន់ក្រៃ ៗ នៅស្ថាននរក
វៀនតែទល់ទុក្ខ ពិតពុំប្រែពៃ ទើបសុន្ទរ- ល័យរាកាចក្រៃ រកកលថាហៃ
ធនញ្ជ័យបណ្ឌិត ៗ អញដណ្ដឹងទៅ ចូរប្រាប់ដោយទូវ ពាក្យទៀង
ពុំទិត ឲ្យយើងបានដឹង ដំណឹងពាក្យពិត ឲ្យដឹងគំនិត អ្នកកុំសង្កា ៗ ទៅ
បានធ្វើគុណ ទឹងស្ដេចលើសលន់ ឬមួយក្សត្រា ធ្វើគុណទឹងទៅ ច្រើន
នៅអាត្មា ទៅប្រាប់យើងក៏ ឲ្យដឹងសេចក្ដី ៗ ពោធិសត្វឆ្លើយ ថាអា-
ចារ្យអើយ ព្រះបាទចក្រី ព្រះអង្គសាងធ្វើ គុណលើសសិរសី អញច្រើន
គតបី ឥតបើគណនា ៗ អញសោតសឹងធ្វើ គុណតាប់ទៅលើ ក្សត្រ
ក្សាន្តថ្ងៃថា សុន្ទរភ័យ ស្រដីទៅថា ឥឡូវនេះណា ចិត្តទៅសព្វថ្ងៃ ៗ
ទៅដឹងព្រះគុណ ក្សត្រថ្លៃលើសលន់ ឬមួយក្សត្រថ្លៃ , ព្រះអង្គដឹងគុណ
ទៅពន់ពេកក្រៃ ថ្លែងកុំសង្ស័យ អស់យើងនេះណា ៗ អ្នកថាខ្ញុំទឹក
គុណក្សត្រយប់ព្រឹក សព្វទិនទិវា ឯក្សត្រឧត្តម អញដឹងហើយណា
កងព្រះទ័យា ពុំហ៊ានថាឡើយ ៗ អាចារ្យទាំងបី ស្ដាប់ព្រះពោធិ- សត្វ
ដូច្នោះហើយ មានចិត្តត្រេកអរ សាទរខ្លះឆ្លើយ ថាធនញ្ជ័យអើយ
យើងសួរទៅទៅ ៗ ទើបបបួលគ្នា ចុះចាកសាលា ដើរដល់ផ្លូវក្រៅ

សុន្ទភល័យ ស្រដីចៅពៅ អួតថាយើងទៅ លួងលោមបានការ ។
អស់គ្នាយើងកុំ ធុញថប់បារម្ភ គនគិតសាភ អត្តឲ្យអញឯង សំដែង
កិច្ចការ កិច្ចវាឲ្យបាន ចុះចាញ់ចំណេះ ។ យើងទៅទូលកិច្ច ញុះញង់
ឲ្យស្ដេច សម្លាប់វានេះ កុំឲ្យវាច្រើន លើយើងដូចេះ គិតហើយវាង
វេះ ទៅផ្ទះគ្រប់ប្រាណ ។ ព្រះពោធិសត្វ មហាបុរសរតន៍ ក្រោយ
នោះអ្នកមាន ព្រះទ័យគន់គិត ក្នុងចិត្តពុំក្សាន្ត ថាវាលួងបាន ពាក្យ
អញនេះណា ។ វាទៅពាំ ពាក្យពីនេះនាំ ឲ្យខុសអាត្មា លង់
លុះព្រឹកព្រាង ស្រេចស្រាងអស់អា- ចារ្យនូវព្រះមហា- បុរសរតន៍
ថ្ងៃ ។ ឡើងគាល់មហាក្សត្រ ឱនអង្គប្រណិប័តន៍ គ្រប់តួទទៃ អង្គុយ
គ្រប់ប្រាណ នៅស្ថានប្រពៃ សុន្ទភល័យ ក្រាបទូលក្សត្រា ។
បពិត្រភូមិន្ទ នាពយណ៌នរិទ្ធ- ធិបតីពជា ឲ្យចៅធនញ្ជ័យ កាចក្រៃ
សោះសា លើសគុណក្សត្រា អម្ចាស់សិរសើ ។ កាលនោះមហាក្សត្រ
បើកបន្ទូលថ្វាត់ ថាហេតុដ្បិតអ្វី ព្រះស្ដែងតើដឹង ដំណឹងអំពី ដំណើរ
ដូចម្ដេច ចូរចៅចរចា ។ អាចារ្យទាំងបី ក្រាបទូលវង្វើ កាលខ្ញុំករុណា
ទាំង ៣ ដើរទៅ លំនៅសាលា ធនញ្ជ័យបរចា ពីម្សិលនោះនៃ ។ ថា
គាត់ធ្វើគុណ ទឹងម្ចាស់ច្រើនលន់ ហើយអម្ចាស់ថ្លៃ មានគុណទឹងគាត់
ច្រើនក្លាត់ពេកក្រៃ គាត់ឯងសព្វថ្ងៃ គិតគុណក្សត្រា ។ ឯព្រះអង្គក្សត្រ
ពុំគិតគុណគាត់ ដល់តិចឡើយណា មួយសោតគាត់ថ្លែង សំដែងចរចា

ថាបើនរណា គាប់គុណគេហើយ ៗ រំលែសទេវតា លោកតែងបក
មុខមិនលែងឡើយ ឲ្យជាកាក្រក់ ជាទុក្ខពុំស្បើយ ដល់លោកឥតត្រើយ
ផលបរលោកទាយ ៗ ទីងទៅសោយទុក្ខ នៅនានរក ចតុកបាយ ពាក្យ
គាត់នេះជៀល បញ្ចៀសពីទាយ ឲ្យក្រិតពណ្ណកាយ ពុំដែលឡើយ ៗ
ស្តេចជ្រាបព្រះទ័យ សុទ្ធកល័យ ទូលដូច្នោះហើយ ទ្រង់ព្រះក្រោធ
ក្រៃ ព្រះទ័យពុំស្បើយ ថាធនញ្ជ័យអើយ មែនពិតឬអ្វី ៗ ពង្ស
ពោធិសត្វ ទៀងទូលទៅថ្វាត់ ថាខ្ញុំស្រដី ពិតពាក្យពុំកៀស បញ្ចៀស
បក្រិ អាចារ្យទាំងបី គេមកបូលកាច់ ៗ ខ្ញុំថាមិនដឹង មិនមានដំណឹង
ក្នុងព្រះទ័យស្តេច ដ្បិតខ្ញុំមិនបាន ផល់ស្ថានសម្រេច អរហត្តផលផ្តាច់
វដ្តសង្សារសោះ ៗ យន់យល់សព្វសា- រពើពីហា- ទ័យទៀងចំពោះ
មួយសោតខ្ញុំថា អ្នកណាមួយនោះ គេ្ចគុណគេសោះ អស់ទាំងទេ-
ពតា ៗ តែងបកមុខ ពិតពុំមានសុខ ក្នុងអង្គកាយា ពិតពីមុនមាន
ទំពាទបង់ជា ច្បាប់ច្បាស់ប្រុះប្រា- កដកុំសង្ស័យ ៗ សម្តេចក្សត្រា
បើកបន្ទូលថា ម្តេចចៅធនញ្ជ័យ បូរចៅតាតែង ថ្វាថ្លែងប្រស្រ័យ ឲ្យ
ដឹងអាថ៌ទៃ ដើមទង់ទិទាន ៗ

ពោធិសត្វទឹក គន់គិតត្រៀក ជាតិសព្វញ្ញាណ អ្នកនាំនិយាយ
តែងតាយទិទាន បុរសមួយមាន ចិត្តល្មិលគុណគ្រូ ៗ ទៀងទើប
ទូលថា បពិត្រក្សត្រា ជាមកុដឥតគូ កាលកន្ទងលង់ ព្រះអង្គឯងកូវ

កបកើតនិត្យនៅ ជាតិជាក្សត្រា ។ នាមព្រះព្រហ្មទត្ត សោយកផសម្បត្តិ គ្រប់គ្រងសីមា ពាពណសី សេនីយសេនា សម្រាប់ព្រះមហាក្សត្រក្សាន្តស្ងួ ។ ឯអគ្គពុជព្រាហ្មណ៍ អន្ទោលទៅតាមកើតកបមួយមូល យោនយកជាតិជា វង្សត្រកូល ព្រាហ្មណ៍ព្រឹទ្ធអំបូរ បុរោហិតា ។ គាត់បង្កើតបុត្រ កូនប្រុសបរិសុទ្ធ មួយមានរូបាទើបមកសន្មត ប្រាកដនាមា ឲ្យហៅឈ្មោះជា ទិព្វសរកុមារ ។ គឺអគ្គសេនាបតីកើតជា កូនគាត់គាប់កាល នោះនៃហេតុកម្ម នោះនាំបណ្ដាល រំលស់រំបាល បៀតបៀនឲ្យស្លាប់ ។ រងែកតាំងផ្ទះ ស្ងប់ស្ងាត់វគ្គះ សោះសូន្យផុតធាប់ ទិព្វសរកុមារ ម្ដាប្រញាប់ រត់រត់ក្រឡាប់ ចរចោលគ្រឹហា ។ ស្វែងស្វះរករៀន សិល្បសាស្ត្ររៀន ទាល់តក្កសិលា ចូលទៅសំណាក់ អាស្រ័យទិសាបាមោក្ខជាអាចារ្យចែងប្រដៅ ។ លុះកាលបើរៀន សិល្បសាស្ត្ររៀនចេះចប់ជ្រះជ្រៅ សំពះក្រាបលា គ្រូបានីងទៅ ទីស្ថានលំនៅ តំបន់គ្រឹហា ។ គ្រប់មើកស្ថានស្មោះ ដើរដល់ស្រុកឈ្មោះ បច្ចន្តគ្រាមាកាលនោះខ្ញុំឯង ពីព្រែងនាយណា យោនយកជាតិជា ចណ្ឌាលមាណព ។ ឥតញាតិពង្សា មោះមានប្រាជ្ញា ចេះមន្តសព្វគ្រប់ មន្តមួយពិស្ដារ ត្រកាលតែងជប្ប សារពើឈើសព្វ ឥតផ្លែជប្បបាន ។ មន្តនោះនិមិល ស្មោះអកាលផល បើចិត្តគិតច្បាន ប្រាថ្នាផ្លែឈើ

សោរពើសឹងបាន បៀមទឹកព្រួសថ្កាន កើតផ្លែច្រើនក្រៃ ៗ បណ្ដាល មាណព ចិត្តគិតចង់ជប្ប មានកាលមួយថ្ងៃ បរិភោគបាយទឹក ពីព្រឹក ហើយនៃ ដើរដល់ក្នុងព្រៃ យល់ដើមស្វាយនោះ ៗ បណ្ដាលមាណព ស្ទុះស្ទាញស្ទាបស្ទប ពានឡើងស្ពានស្ពោះ ប្រាំពីរដំទែង សំដែងមន្ត នោះ កើតផ្លែបេះបោះ ពោលជាសរដេរដី ៗ មាណពចុះមក ជ្រើសរើស យក ដាក់កញ្ជើ ហើយបរិភោគា អាហារពិសា ពិសាហាក់ពី ស្នូកទេពប្រពៃ ៗ ហើយទើបមាណព រែកផ្លែឈើជប្ប បរចេញពីព្រៃ មកលក់ដូរជា ទ្រព្យប្រសើរ បរិភោគសព្វថ្ងៃ ចិញ្ចឹមភរិយា ៗ ទិព្វសរកុមារ យល់មន្តអករល- ផលនោះប្រាជ្ញា ប៉ុនប៉ងទៅរក រៀន យកម្ទីមា នឹងនាំយាត្រា ទៅឋានទនេរ ៗ មានថ្ងៃមួយមា- ណពនោះលី- លា លះលាកចេញចរ ចូលព្រឹក្សព្រៃជ្រៅ ឯចៅទិព្វសរ- កុមារសាទរ ទៅទាល់គ្រឹហា ៗ ឈរឈប់ទិត្យនៅ ជិតជណ្ដើរហៅ ជណ្ដឹងទៅ ថា អ្នកគ្រូលោកនៅ ឬទៅឯណា ប្រពន្ធគ្រូថា គាត់ចេញទៅព្រៃ ៗ ទិព្វសរកុមារ នៅចាំអាចារ្យ លង់លុះល្ងាចថ្ងៃ មាណពលីលា ក្រ- ឡាប់ពីព្រៃ បុរសវិលវៃ ទៅទទួលគ្រូ ៗ ចេញទៅពីផ្ទះ ដើរដល់ ប្រទះ និត្យនៅខាងផ្លូវ លុតជង្គង់ហើយ ឆ្លើយថាអ្នកគ្រូ ខ្ញុំមកឥឡូវ ចាំទទួលអ្នក ៗ ហើយយកកញ្ជើ អង្រែមកដាក់លើ ស្មាស្មោះដើរ ដាក់ ដូចដល់លំនៅ ចូលទៅសំណាក់ ផ្ដាប់ពុំឲ្យភាក់ ឲ្យអន់ចិត្ត ៗ

បំរើសារពើ កិច្ចការផងធ្វើ ហេតុចិត្តប្រាថ្នា ប៉ុនប៉ងរករៀន រៀន
សាស្ត្រា ផ្គាប់ឥតសង្កា ចិត្តត្រូវផល់តិច ៗ មាណពគន់គិត យន់
យល់គំនិត ផ្គាប់សព្វសេចក្រែច ទើបប្រាប់កិរិយា ដោយនាកល
កិច្ច នាងអើយធ្វើម្តេច ចៅនេះផ្គាប់ណាស់ ៗ ហេតុចង់បានមន្ត
ពិសេសទិព្វគន់ រៀនយករហ័ស រីឯមន្តនេះ បើបេះស្លាត់ជ្រះ
បើសប្បុរសណាស់ ពាក្យសត្យឋិតនៅ ៗ បើអ្នកខុំដិន ទីងរៀនយក
មន្ត នេះពុំបានទៅ បើអញអាសូរ អនុកូលប្រដៅ អសារអោសៅ
អសោចសាបសោះ ៗ ទិព្វសរកុមារ ខះខំធ្វើការ បម្រើគ្រូនោះ ដងទឹក
កាប់ឧស អម្រែសល់លុះ ដូចខ្ញុំសុខ្ទសោះ ចាំគក់ប្របាច់ ៗ គ្រូពុំប្រ-
ដៅ បម្រើលង់ទៅ ផ្គាប់ផ្គុនផ្តេកផ្តិត ចិត្តចាប់ចាំបង ប៉ុនប៉ងពុំភ្លេច
លង់លុះទៅតិច កិរិយាមាណព ៗ ប្រសូត្រកូនចេញ បុរសនោះមិញ
ពិតពុំឈរឈប់ ពុះឧសដងទឹក យប់ព្រឹកជួល់ជួប់ បម្រើសព្វគ្រប់
លុះលាងអាចម៍កូន ៗ ផ្គាប់ផ្គុននិត្យនៅ លោកពុំប្រដៅ សិល្បសាស្ត្រ
សោះសូន្យ ហេតុសិល្បសាស្ត្រា ថ្លៃថ្លាទុកទូន- មានមកគួរកូន សិស្ស
សោតបម្រើ ៗ ឯកិរិយាយល់ ចៅនោះខ្វាយខ្វល់ ជួបអស់អំពើ
ពោលពាក្យប្រាប់ប្តី ភាណអើយចេះតែ ចៅនេះបម្រើ លំបាកសព្វ
ថ្ងៃ ៗ គេជាត្រកូល ពូជព្រាហ្មណ៍អំបូរ ប្រសើរថ្លាថ្លៃ គេចូលមក

ធ្វើ បម្រើចេះនៃ គួរកុំសង្ស័យ ប្រដៅគេទៅ ៗ ប្ដីស្លាប់ចោះហើយ ពិតពុំលង់ឡើយ ស្រែកហៅចៅពៅ ទិព្វសរបានដឹង ដំណឹងចូលទៅ ដល់គ្រូប្រដៅ ចាំសព្វសេចគ្រេច ៗ ទើបគ្រូផ្ដាំ ថាចៅចូរចាំ អស់ទាំងពាក្យពេចន៍ អញប្រាប់ឲ្យដឹង ដំណឹងកលកិច្ច ចៅអើយកុំភ្លេច ពាក្យអញចរចា ៗ មន្តនេះពិសេស ជាមន្តទិព្វទេស ប្រសើរថ្លៃថ្លា បើចៅបានដល់ មណ្ឌលនៃអាមាត្យនូវមហាក្សត្រា ប្រើផ្ដាន ៗ ចៅនឹងបានយស ប្រសើរខ្ពង់ខ្ពស់ កបកើតធនធាន បើលោកផ្ដាំង ដំណឹងដោយដាន ចៅប្រាប់កុំមាន សន្ទុះសង្កា ៗ បទអញជាគ្រូ កុំខ្លាចអាស្រូវ ដំនៀលទិន្នា បើចៅពុំបែង សំដែងមុសា មន្តនោះយល់ជា អសារសោបសោះ ៗ រីឯខ្លួនចៅ សោកសឹងអាសៅ អសោចមានមោះ សិស្សសោកចង់ចាំ បណ្ដាំគ្រូនោះ លាគ្រូចរចុះ ដល់ដីដើរទៅ ៗ ប្រទក្សិណបី ជុំស្រេចឃ្លាតទ្វី ស្ពានស្ពោះសំដៅ ត្រាប់ត្រង់ឆ្ពោះឋាន ដល់ឋានលំនៅ ទៀងទើបចូលទៅ ទីឋានអាត្មា ៗ ទិព្វសរកុមារ ជប់មន្តអាគាល កើតជាផលា ស្វាយដោយព្រះមន្ត ទិព្វគន់ថ្លៃថ្លា អ្នកផ្សារម្ខ្មា ទិញយកទៅពៅ ៗ កាលណោះអ្នកឆ្នាំ ឧទ្យានចែងចាំ យល់ស្វាយទុំឆ្មៅ កទិញស្វាយនោះ នាំស្ពោះចូលទៅ ថ្វាយក្សត្របរមចៅ ជាតិជាអម្ចាស់ ៗ ស្ដេចសោយផលា ទៀងទើបក្សត្រា

ត្រេកទ្រង់ត្រាស់ បើកបន្ទូលថា ស្វាយអាផ្អែមណាស់ ចូរអារហ័ស
វិលទៅវិញទៀត ។ ស្វាយនេះចំឡែក អស្ចារ្យផ្អែមប្លែក អាទំឃ្លាំ
ធ្មៀត ខំទិញឲ្យបាន កុំខានបង់សៀត អានោះទៅទៀត រកទិញម្មីម្មា ។
បានស្រេចនាំទៅ ថ្វាយក្សត្រពមហៅ សត្វទិនទិក ទិព្វសរកុមារ
ត្រអាលយាត្រា នាំស្វាយផល ថ្វាយក្សត្រជេស្ឋជ័យ ។ ស្ដេច
ដាក់ប្រទាន មាសប្រាក់ធនធាន ច្រើនពន់ពេកក្រៃ ទិព្វសរកុមារ
ត្រអាលសត្វថ្ងៃ ព្រះបាទក្សត្រថ្ងៃ ទុកព្រះចិន្ដា ។ ស្ដេចបើកព្រះសូរ
មានព្រះបន្ទូល សាកសួរថៃថា ចៅជាគ្រុឌពង នាគពងពិទ្យា- ធរ
ឬទេវតា ចេះមន្ដប្រពៃ ។ ទិព្វសរទូលថា ខ្ញុំនេះណា ជា
មនុស្សវិស័យ ខ្ញុំតែងទងអប- ទេសជប្បសត្វថៃ ស្ដេចឮអរក្រៃ បើក
បន្ទូលថា ។ បើច្នោះព្រះស្ដេង ចេញទៅសំដែង មន្ដសិល្បសាស្ត្រា
ឲ្យអញបានយល់ បុទ្ធចេស្ដា ឲ្យអស់ប្រាជ្ញា ចៅចេះមន្ដនោះ ។
សុរសើរច្នោះហើយ ពិតពុំលង់ឡើយ លុះព្រឹកឡើងស្មោះ ស្ដេចទៅ
ឧទ្យាន ទីឋានក្បែរនោះ ទិព្វសរផ្ដេកផ្ដោះ ចូលក្នុងឧទ្យាន ។
អស់ទាំងសេនា មន្ត្រីយោធា ជួបជុំក្រេមក្សាន្ត ទិព្វសរកុមារ ត្រអាល
ថ្កើងថ្កាន បៀមទឹកស្រេចបាន ពេញមាត់ម្មីម្មា ។

(នៅមានត)

# ពិធីទ្វាទសមាស

តាមទំនៀមព្រាហ្មណ៍ក្នុងនគរពារាណសី (ឥណ្ឌា) ធៀបនឹងទំនៀមខ្មែរ

(ឧកញ៉ា ទេពពិទូរ (ក្រសេម) កត់តាមសេចក្តីឲ្យការរបស់ព្រាហ្មណ៍ ឈ្មោះអច្យុតនន្ទន៍ ដែលមកពីនគរពារាណសីថា

ព្រាហ្មណ៍ដំណែងពេជគ្រ មានមុខការត្រូវធ្វើពិធីទ្វាទសមាសដូចមានតទៅនេះ:

## ពិធីខែចេត្រ

ខែចេត្រ មានពិធី ៤ យ៉ាងគឺ: ពុទ្ធវិធានម៍ ១, ទេវវិធានម៍ ១, ភជវិធានម៍ ១, គជវិធានម៍ ១ ។

ពិធីពុទ្ធវិធានម៍នោះ (គឺពិធីពុទ្ធបូជា) នាថ្ងៃ៥កើតខែចេត្រ ព្រាហ្មណ៍អ្នកធ្វើពិធី ត្រូវងូតទឹកជំរះកាយឲ្យបរិសុទ្ធ ហើយទៅតាក់តែងគ្រឿងសក្ការបូជា គឺផ្កាទៀនធូបគ្រឿងក្រអូប ទឹកសម្រាប់បន្ថែមចំអាបជាចង្ហាន់ ទុកនៅក្នុងវិហារ វត្ថុប៉ាតលីជាស វត្ថុម៉ាដោជាស ហើយអញ្ជើញព្រះមហាក្សត្រ មន្ត្រី រហូតដល់ប្រជារាស្ត្រ ទៅប្រជុំព្រមគ្នា ធ្វើសក្ការបូជាព្រះពុទ្ធរូបតាមសមគួរ ហើយប្រគំតូរ្យតន្ត្រី ស្រេចហើយប្រគេនចង្ហាន់យតិ (ព្រះសង្ឃ) ឆាន់ ពិធីនេះធ្វើតែ ១ ថ្ងៃស្រេច ។

ទេវវិធានម៍នោះ (គឺពិធីបូជានព្វគ្រោះ) ធ្វើនៅថ្ងៃ ៣ កើតខែចេត្រ តាំងរោងពិធីក្នុងព្រះរាជវាំង បូជាទេវតាព្រះគ្រោះទាំង ៩ តាំងឆ្នាំងទឹក ៩

ដូនខ្ចីទៀត ៩ ហើយតាំងប្រទីបលើដូងនោះ ទីងដោតទង់ ៩ ពណ៌ ៩ គឺទង់ព្រះអាទិត្យពណ៌ក្រហមចាស់ ទង់ព្រះចន្ទពណ៌សលឿងខ្ចី ទង់ព្រះអង្គារពណ៌ក្រហមខ្ចី ទង់ព្រះពុធពណ៌លឿង ទង់ព្រះព្រហស្បតិ៍ពណ៌មាស ទង់ព្រះសុក្រពណ៌ស ទង់ព្រះសៅរ៍ពណ៌ខ្មៅ ទង់ព្រះរាហូពណ៌ផ្សែងភ្លើង ទង់ព្រះកេតុផ្សំពណ៌ទាំង ៨ ខាងដើមមកជាពណ៌ទង់ព្រះកេតុ តែងតាំងបូជាអស់រយៈ ៩ ថ្ងៃ ។

ពិធីរាជវិធានម៍នោះ ( គឺពិធីស្រង់រំដោះព្រះគ្រោះ ) ធ្វើនៅថ្ងៃ ១១ កើតខែចេត្រ ដោយព្រាហ្មណ៍អ្នកធ្វើពិធីយកទឹក ៩ ឆាំង ដែលបូជាព្រះនព្វគ្រោះពីថ្ងៃមុនទៅស្រោចស្រង់ព្រះមហាក្សត្រ ព្រះមហេសី ព្រះរាជបុត្ត ព្រះប្រយូរវង្ស ទីងសេនាបតី មន្ត្រី រាជបុរសគ្រប់ដំណែង ស្រេចហើយព្រះមហាក្សត្រទ្រង់គ្រឿងរាជកកុធភណ្ឌសម្រាប់ព្រះមហាក្សត្រ ចេញទ្រង់ស្ដីការរាជការ ពួកសេនាបតីទីងរាជបុរសត្រូវតែងខ្លួនតាមដំណែងចូលគាល់ព្រមគ្នា លំដាប់នោះព្រះមហាក្សត្រទ្រង់ប្រទានព្រះរាជទ្រព្យឲ្យព្រាហ្មណ៍អ្នកធ្វើពិធី ។

ពិធីគជវិធានម៍នោះ ( គឺពិធីបង្ក្រាប់ប្រស់ទិដំរី ) ធ្វើនៅថ្ងៃ ៣ កេចខែចេត្រ ភ្នាក់ងារដំរីតែងគ្រឿងដំរីព្រះទីន័ង ព្រះមហាក្សត្រទ្រង់គ្រឿងរាជកកុធភណ្ឌគង់លើដំរីព្រះទីន័ងនោះ ពួកសេនាបតីទីងអមាត្យទាំងពួងតែងខ្លួនតាមដំណែង ជិះដំរីចងគ្រឿងហែស្ដេចជុំវិញព្រះរាជវាំង ដំរី

ឈ្មោលគេគូររូបព្រះអាទិត្យដាក់នៅមុខ ដំរីញីគេគូររូបព្រះចន្ទ្រដាក់នៅមុខ ព្រាហ្មណ៍ពជគ្រូចាំប្រស់ទឹកព្រួតទឹកស័ង្ខ ។

## ពិធីខែពិសាខ

ខែពិសាខមានពិធីតែ ១ ហៅថា វិសាខវិធានម៍ (គឺពិធីបូជាទេវតារក្សាអាកាសទិសដ៏) ធ្វើនៅថ្ងៃ ១ កើតខែពិសាខ តាំងផ្តាំងទឹក ៥ ដូងឡៅ ៥ សម្រាប់ចំអាប ៥ បង្អែម ៥ និងទៀនធូបភ្ញីផ្កាបូជាក្នុងព្រះពជស្ថាន និងនៅផ្ទះមន្ត្រី សេដ្ឋី គហបតី អ្នកមានទ្រព្យច្រើន បូជាទេវតា ៥ អង្គដែលជាអ្នករក្សាអាកាសទិសដ៏ គឺ មហាបរ់ (មហាសិរ?) ១ សុរិយ ១ វិឃ-ណេសូ ១ គេសរៈ១ គេសិទី ១ ។ ព្រាហ្មណ៍ពជគ្រូទៅធាក់ការបូជាគ្រប់ផ្ទះសម្បែងគ្រប់ ៣ ថ្ងៃហើយ យកទឹកមន្តទាំង ៥ ផ្តាំងនោះទៅស្រោចស្រង់ព្រះមហាក្សត្រ រហូតដល់អមាត្យ មន្ត្រី សេដ្ឋី គហបតី ស្រោចហើយព្រះមហាក្សត្រ និងអមាត្យ មន្ត្រី សេដ្ឋី គហបតិ អ្នកមានសម្បត្តិក៏តាំងធានគ្រប់ៗផ្ទះ តាមមានច្រើនមានតិច សម្រាប់ឲ្យដល់ដំណើរ អស់រយៈ ៣ ថ្ងៃ លុះដល់ថ្ងៃ ១៥ កើតក៏ព្រមគ្នាទៅកាន់ព្រះមហាពោធិព្រឹក្ស ធ្វើសក្ការបូជាព្រះមហាពោធិព្រឹក្ស ប្រគំត្រៃស័ង្ខតុរិយតន្ត្រី ជាការទក្ខតឫក្សដ៏ធំ ។

(នៅមានត)

## ប្រទេសអាមេរិកកណ្ដាល

ប្រទេសអាមេរិកកណ្ដាល មានអាណាខេត្តនិងទំហំដីប្រហែលប៉ុនឥណ្ឌូស៊ីនបារាំងសែសលើសខ្វះបន្តិចបន្តួច ប្រកបដោយរដ្ឋផ្សេងៗរួម៦រដ្ឋ គឺក្វាតេម៉ាឡា ១ ហុងឌុយរ៉ាស ១ នីការ៉ាក្វ ១ សល្វាឌរ ១ កូស្តារីកា ១ ប៉ាណាម៉ា ១ ទាំង៦រដ្ឋនេះជាឯករាជ្យ មានរបៀបគ្រប់គ្រងស្រុកបែបប្រជាធិបតេយ្យ មានរដ្ឋៈជាចំណុះប្រទេសអង់គ្លេស ១ ទៀតហៅថា ហុងឌុយរ៉ាសផែរ ។

ផ្ទៃផែនដី — ជាទីកបខ្ពស់ មានភ្នំភ្លើងជាច្រើន ជាហេតុនាំឲ្យកើតផែនដីកម្រើកជារឿយៗ ទីកបខ្ពស់នោះលាតចុះទៅទិសខាងកើត នាំឲ្យមានដីទំនាបនៅតំបន់តាមដាយសមុទ្រខាងមហាសមុទ្រអត្លង់ទិក ដីទំនាបនេះដាំដំណាំល្អណាស់ ។ ទន្លេសំខាន់ឈ្មោះសានហ្វាន (១៩២ គីឡូម៉ែត្រ) ហូរធ្លាក់ទៅក្នុងទន្លេសាបនីការ៉ាក្វ ។

ខ្យល់អាកាស — មានអាកាសក្ដៅ មានភ្លៀងធ្លាក់ច្រើនដូចជាប្រទេសទាំងពួងដែលតាំងនៅជិតខ្សែសូន្យ តែលើទីកបខ្ពស់កំដៅអាកាសអន់ក្ដៅបន្តិច ។

ដំណាំ — ស្រូវខ្សាយ, កាហ្វេ, កាកាវ, អំពៅ, ចេក, ដូង, កៅស៊ូ, ថ្នាំជក់, ពោត, ត្រុំជាដើម ។

✓ សត្វ — គោ កែះ សេះទឹងផ្ទះគេចិញ្ចឹមទុកជាច្រើន ។

ជំនួញលក់ចេញ — កាហ្វេ, ចេក, ស្បែកសត្វ, ឈើសម្រាប់ផលក់សំពត់, ស្ករ, ដូង, ក្រំ, គោ, ឈើ ។ល។

ប្រជាជន — ជាជាតិឥណ្ឌៀនពួកកូនកាត់ (អេស្ប៉ាញ៉ុលកាត់ឥណ្ឌៀន) ជាច្រើន មានចំនួនប្រមាណ ៧.០០០.០០០ នាក់ កាន់គ្រិស្តសាសនា លទ្ធិកាតូលិក ។

ប្រទេសក្វាតេម៉ាឡា — មានទំហំដីប្រមាណ ១២៥, ០៧០ គីឡូម៉ែត្រក្រឡា មានមនុស្សចំនួនជាង ២លាន ទីក្រុងឈ្មោះក្វាតេម៉ាឡា លោហធាតុមាន មាស ប្រាក់ ទង់ដែង ។ ទន្លេសំខាន់ឈ្មោះម៉ងតាក្វប្រវែង ៤០០ គីឡូម៉ែត្រ ។ ជំនួញលក់ចេញដែលសំខាន់បំផុតគឺកាហ្វេ (៦០% របស់ជំនួញទាំងអស់) ស្ករនឹងចេក ។

ប្រទេសហុងឌុយរ៉ាស — មានទំហំដី ១១៤,៦៧៦ គីឡូម៉ែត្រក្រឡា មានមនុស្សប្រមាណ ៩០០, ០០០ នាក់ ទីក្រុងឈ្មោះតេគុយស៊ីកាល់ប៉ា ទន្លេសំខាន់ឈ្មោះសេកូវី (៥៦០ គីឡូម៉ែត្រ) មានត្បូងថ្ម, មាស, មាសស, ប្រាក់ទីនដែក, ទ្រយស៊ីល្មោជាស្រុកកំពង់ អ្នកស្រុកគេស៊ីធ្វើស្រែនឹងចិញ្ចឹមគោ, ជំនួញលក់ចេញដែលសំខាន់បំផុត

គឺចេកអំបូង មានដល់ទៅជា ៧៩% នៃផលដំណាំលក់ចេញទាំងអស់ ក្នុង ព. ស. ២៤៧៧ មានចំនួនចេកអំបូងលក់ចេញទៅក្រៅប្រទេស ដល់ ១៩.៤៦២.៥៩៦ ស្ទង ជាប្រាក់ជាង ២០ លានរៀល ។

ប្រទេសហុងឌុយរ៉ាសរបស់អង់គ្លេស — មានទំហំដី ២២,២៦៨ គីឡូម៉ែត្រក្រឡា មានមនុស្សប្រមាណ ៥២,០០០នាក់ បេលិសជាទីក្រុង ។ ផលដំណាំលក់ចេញមាន ចេក, កាហ្វេ និងឈើម៉ះហ៊កកានី ។

ប្រទេសនីការ៉ាក្វ — មានទំហំដី ១៣៣,៨០០ គីឡូម៉ែត្រក្រឡា មានមនុស្ស ៨០០,០០០ នាក់ ទីក្រុងឈ្មោះម៉ាណាក្វ ។ លោហធាតុមានមាស ប្រាក់ ។ ផលដំណាំលក់ចេញដែលសំខាន់ គឺកាហ្វេ, ចេក, អំពៅ, កៅស៊ូ ។

ប្រទេសសាល់វ៉ាឌ័រ — មានទំហំដី ៣៤,១២៦ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ១,៥៣០,០០០ នាក់ ជាប្រទេសតូចបំផុត តែមានមនុស្សច្រើនបំផុត នៅអាមេរិកកណ្ដាល ។ ផលដំណាំលក់ចេញដែលសំខាន់គឺកាហ្វេ, ត្រី, និងចេក ។ ប្រទេសនេះមានភ្នំភ្លើងច្រើន មានផែនដីកំរើកជារឿយៗ ។

ប្រទេសកុស្តារីកា — មានទំហំដី ៥៩,៥៧០ គីឡូម៉ែត្រក្រឡា ចំនួនមនុស្សក្នុង ព. ស. ២៤៧៣ មានចំនួន ៥៦១.០៣១ នាក់ ទី

ក្រុងឈ្មោះសង់ស្វ៉ែ កាហ្វេទីងចេកជាជំនួញលក់ចេញដែលសំខាន់បំផុតប្រមាណ ៩០% ។

**ប៉ាណាម៉ា** — មានទំហំដី ១១៤,៩០០ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ៨០០,០០០ នាក់ រីក្រុងឈ្មោះប៉ាណាម៉ា អ្នកស្រុកធ្វើស្រែចំការទីងរកស៊ីសត្វដូចមុខ ។ ជំនួញលក់ចេញដែលសំខាន់គឺចេក(៦០%) កាកាវ, ដូង, ខ្យង, ត្បូងខ្យង ផ្សេងៗ ។

ព្រែកជីកប៉ាណាម៉ាដែលភ្ជាប់មហាសមុទ្រប៉ាស៊ីហ្វិក នឹងមហាសមុទ្រអាត្លង់ទិកនៅក្នុងប្រទេសនេះ ព្រែកនេះបណ្តោយ ៨០ គីឡូម៉ែត្រ ទទឹងជាង៩០ម៉ែត្រ គួរកប់ថាជាព្រែកជីកដែលធំទូលាយបំផុតក្នុងលោក ។ មាននាវាតូចធំចេញចូលតាមព្រែកជីកនេះក្នុង ១ ឆ្នាំៗ ប្រមាណ ៣០០០ សហរដ្ឋអាមេរិកជាអ្នកជីកហើយជាម្ចាស់ព្រែកជីកនេះផង ។

## ពួកកោះផ្សេងៗនៅភាគទិសខាងលិច

មានកោះផ្សេងៗជាច្រើនតាំងពីផ្លោរីដចុះទៅដល់ប្រទេសវេនេស៊ុយឡា គួរបែងចែកជា ៣ ពួក គឺ:

(១) ពួកកោះអង់ទីយធំ មានកោះគុយបា, ហៃទី, សាម៉ាអ៊ីកនឹងប៉ូតូរីកូជាសំខាន់ (២) ពួកកោះអង់ទីយតូច ប្រកបដោយកោះតូចៗជាច្រើន ដែលសំខាន់គឺកោះទ្បាទ្រីនីតេ (៣) ពួកកោះបាហាម៉ា ។

គុយបា — ជាប្រទេសឯករាជ្យ មានរបៀបត្រួតត្រាស្រុកជាបែបប្រជាធិបតេយ្យ មានទំហំដី ១១៤, ៣៨៤ គីឡូម៉ែត្រក្រឡា ជាកោះធំបំផុតក្នុងចំណោមកោះអស់នោះ ។ កោះនេះមានអាកាសធាតុល្អជាងពួកកោះដទៃទៀត ។ ដំណាំសំខាន់បំផុតគឺអំពៅ (ច្រើនបំផុតក្នុងលោក) ថ្នាំជក់ទឹកពោត ដំណាំបន្ទាប់មកមានស្រូវ កាហ្វេ កប្បាស កាកាវ ។ គោមានចំនួនចិញ្ចឹមច្រើន ទន់ដែនដីកប្រាក់ច្រើនជាងលោហធាតុឯទៀតៗ ។ ផលិតផលចេញ មានស្ករ (ច្រើនបំផុត) ថ្នាំជក់ បារី ទន់ដែង ។ ប្រជាជនមានចំនួន ៤, ០១១,០៨៨ នាក់ (ក្នុង ព.ស. ២៤៧៦) មានពូជអេស្ប៉ាញ៉ុលជាច្រើន ។

ហៃទី — កោះនេះបែងចេញជាប្រទេសរេពុយព្លិក ២ ប្រទេសគឺហៃទីនឹងសាំងដូម៉ាំង ។ កោះនេះមានផែនដីកម្រើកនឹងខ្យល់ព្យុះជារឿយៗ សម្បត្តិផែនដីដែលសំខាន់ គឺកប្បាស ស្រូវ ពោត អំពៅ កាហ្វេមាស ប្រាក់ ដែកនឹងទន់ដែង ។ ប្រទេសនេះមានទំហំដី ៧២, ៤២៨ គីឡូម៉ែត្រក្រឡា ។ ប្រជាជនចំនួន ២, ៥៥០,០០០ នាក់,ផលិតផលចេញដែលសំខាន់ គឺកាហ្វេ កាកាវ ថ្នាំជក់នឹងឈើ ។

សាមាអ៊ិក — ជាកោះរបស់អង់គ្លេស មានខ្នាតធំនឹងសំខាន់ជាងកោះឯទៀតៗរបស់អង់គ្លេសក្នុងពួកកោះអង់ទីយ៍ ។ មានទំហំ១១.៥២៥

គីឡូម៉ែត្រក្រឡា ។ ប្រជាជនចំនួន ៩០០,០០០ នាក់ សម្បត្តិផែនដី មានចេក កាហ្វេ ខ្ទិះ កាកាវ ស៊ីនកូណា ឈើ ផ្លែឈើ ។ ជំនួញលក់ចេញដែលសំខាន់គឺចេកអំបូង មានដំឡៃដល់ទៅជាង ២៦ លានរៀលក្នុង ព.ស. ២៤៧៣ ។

ប៉ូរតូរីកូ — ជាកោះចំណុះរបស់អាមេរិក មានទំហំដីប្រមាណ ៨,៨៩៦ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ១,៦០០,០០០ នាក់ មានអាកាសល្អ មានមនុស្សនៅច្រើន ។ ស្ករសជាជំនួញលក់ចេញសំខាន់បំផុត ចំណាយក្នុង ១ ឆ្នាំ ប្រមាណ ៧ សែនតោន ជំនួញបន្ទាប់មកគឺថ្នាំជក់និងមាស់ ។

ចប់ភូមិសាស្ត្រសង្ខេប

ប្រទេសអាមេរិកកណ្ដាល តែប៉ុណ្ណេះ ។

## ពង្សាវតាររោម

(តមក)

ហេតុទាស់ទែងទំនងនេះហើយ ដែលនាំឲ្យសេសារនិងប៉ុមប៉េជាសត្រូវនឹងគ្នាយ៉ាងធំ ៗ ឯសេសារក៏ចាប់ធ្វើការដូចជាមេទ័ពមុនៗធ្លាប់ធ្វើមកហើយ គឺលើកទ័ពចូលក្រុងរោម ៗ

ហេតុភេទទំនងនេះ មិនមែនជាការដណ្តើមអំណាចក្នុងរវាងពួកក្រុមពីរពួកទេ គឺជាការប្រណាំងប្រជែងគ្នាក្នុងរវាងមនុស្ស ២ នាក់ ឯប៉ុមប៉េដែលពោលកងទ័ពខ្លួនទុកនៅប្រទេសអេស្ប៉ាញនោះ ក៏មិនមានកំឡាំងអ្វីនឹងតស៊ូទប់ទល់នឹងសេសារបាន ទើបគេចរត់ចូលទៅក្នុងប្រទេសក្រិក ឯពួកសមាជិកសភាសេណាត ក៏ក្រែងខ្លាចអំណាចសេសារក៏នាំគ្នារត់តាមប៉ុមប៉េទៅ ៗ កាលបើដូច្នេះ សេសារក៏មានអំណាចធំបំផុតនៅក្នុងក្រុងរោម លុះចាត់រៀបចំក្រុងរោមរៀបរយហើយ ក៏ចេញទៅប្រទេសអេស្ប៉ាញ ដើម្បីប្រមូលយកកងទ័ពរបស់ប៉ុមប៉េមកទុកក្នុងអំណាចខ្លួនផង ក្នុងការចេញទៅនេះ សេសារវាយយកបានស្រុកម៉ារ្សៃយ ១ ផង រួចហើយទើបឆ្លងសមុទ្រអាទ្រីយ៉ាទិក (Adriatique) ទៅវាយទ័ពប៉ុមប៉េបែកខ្ចាត់ខ្ចាយអស់ ឯប៉ុមប៉េរត់ទៅប្រទេសអេស៊ីប្ត គ្រាន់តែឡើងផុតពីទូកក៏មានមនុស្សលបសម្លាប់ទៅ ៗ

ក្រុងឈ្មោះសង់ស៊ូស៍ កាហ្វេនឹងចេកជាដំនួញលក់ចេញដែលសំខាន់បំផុតប្រមាណ ៩០% ។

**ប៉ាណាម៉ា** — មានទំហំដី ១១៤, ៤៩០ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ៥០០,០០០ នាក់ រីក្រុងឈ្មោះប៉ាណាម៉ា។ អ្នកស្រុកធ្វើស្រែចំការនឹងរករើសត្បូងខ្យងមុក្តា ។ ដំនួញលក់ចេញដែលសំខាន់គឺចេក(៦០%) កាកាវ, ដូង, ខ្យង, ត្បូងខ្យងមុក្តា ធ្យូងថ្ម ។

ព្រែកជីកប៉ាណាម៉ាដែលភ្ជាប់មហាសមុទ្រប៉ាស៊ីហ្វិក នឹងមហាសមុទ្រអត្លង់ទិកនៅក្នុងប្រទេសនេះ ព្រែកនេះបណ្តោយ ៨០ គីឡូម៉ែត្រ ទទឹងជាង៩០ម៉ែត្រ គួរកប់ថាជាព្រែកជីកដែលធំទូលាយបំផុតក្នុងលោក ។ មាននាវាតូចធំចេញចូលតាមព្រែកជីកនេះក្នុង ១ ឆ្នាំៗ ប្រមាណ ៣០០០ សហរដ្ឋអាមេរិកជាអ្នកជីកហើយជាម្ចាស់ព្រែកជីកនេះផង ។

## ពួកកោះផ្សេងៗនៅភាគទិសខាងលិច

មានកោះផ្សេងៗជាច្រើនតាំងពីជ្រោយហ្វ្លរីដចុះទៅដល់ប្រទេសវេនេស៊ុឡា គួរបែងចែកជា ៣ ពួក គឺ:

(១) ពួកកោះអង់ទីយធំ មានកោះគុយបា, ហៃទី, សាម៉ាំងគ៍នឹងប៉ូតូរីកូជាសំខាន់ (២) ពួកកោះអង់ទីយតូច ប្រកបដោយកោះតូចៗជាច្រើន ដែលសំខាន់គឺកោះឡាទ្រីនីតេ (៣) ពួកកោះបាហាម៉ា ។

គុយបា — ជាប្រទេសឯករាជ្យ មានរបៀបត្រួតត្រាស្រុកជាបែបប្រជាធិបតេយ្យ មានទំហំដី ១១៤,៣៨៤ គីឡូម៉ែត្រក្រឡា ជាកោះធំបំផុតក្នុងចំណោមកោះអស់នោះ ។ កោះនេះមានអាកាសធាតុល្អជាងពួកកោះជិតខាង ។ ដំណាំសំខាន់បំផុតគឺអំពៅ (ច្រើនបំផុតក្នុងលោក) ថ្នាំជក់ទឹកពោត ដំណាំបន្ទាប់មកមានស្រូវ កាហ្វេ កប្បាស កាកាវ ។ គោមានចំនួនចិញ្ចឹមច្រើន ទន់ដែកដីកប៉ុនច្រើនជាងលោហធាតុឯទៀតៗ ។ ជំនួញលក់ចេញ មានស្ករ (ច្រើនបំផុត) ថ្នាំជក់ ប៉ារី ទន់ដែក ។ ប្រជាជនមានចំនួន ៤,០១១,០៨៨ នាក់ (ក្នុង ព.ស. ២៤៧៦) មានពូជអេស្ប៉ាញ៉ុលជាច្រើន ។

ហៃទី — កោះនេះបែងចេញជាប្រទេសរេពុយព្លិក ២ ប្រទេស គឺហៃទីនឹងសាំងដូមិង្គ ។ កោះនេះមានផែនដីមេម្រិកនឹងខ្យល់ព្យុះជារឿយៗ សម្បត្តិផែនដីដែលសំខាន់ គឺកប្បាស ស្រូវ ពោត អំពៅ កាហ្វេ មាស ប្រាក់ ដែកនឹងទន់ដែក ។ ប្រទេសនេះមានទំហំដី ៧២,៤២៨ គីឡូម៉ែត្រក្រឡា ។ ប្រជាជនចំនួន ២,៥៥០,០០០ នាក់, ជំនួញលក់ចេញដែលសំខាន់ គឺកាហ្វេ កាកាវ ថ្នាំជក់នឹងឈើ ។

សាមាអ៊ិក — ជាកោះរបស់អង់គ្លេស មានខាងធំនឹងសំខាន់ជាងកោះឯទៀតៗរបស់អង់គ្លេសក្នុងពួកកោះអង់ទីយ៍ ។ មានទំហំ ១១.៥២៥

# រឿងព្រះចៅអសោក
(តមក)

ក្នុងខែត្រដែលព្រះបាទអសោកបញ្ជូនព្រះថេរទៅប្រកាសព្រះពុទ្ធ-
សាសនានេះ មានខ្លះជាដែនដែលមិនបាននៅក្នុងអំណាចរបស់ព្រះអង្គតែ
អាស្រ័យហេតុដែលព្រះអង្គមានអំណាចជាធំក្រៃលែងនៅក្នុងឥណ្ឌា ទើប
មិនមានអ្នកណាហ៊ានឃាត់ទាំងឡើយ ហើយកាលនោះព្រះពុទ្ធសាសនា
ជាសាសនាដែលដោះទុក្ខរបស់មនុស្សបានពិត ៗ ដូច្នេះ អ្នកប្រទេសទាំង-
ឡាយក៏ជ្រះថ្លាជាច្រើន ម្យ៉ាងទៀត បណ្ដាលោកអ្នកដែលប្រកាសព្រះ
ពុទ្ធសាសនានេះ ក៏បានធ្វើប្រយោជន៍ដ៏សំខាន់ឲ្យដល់អ្នកប្រទេសខ្លះទៅ
ដូចក្នុងដែនដិក្កាន់ (Dek-kan) ដែលវេលានោះនៅជាមនុស្សព្រៃនៅឡើយ
ក៏បានទទួលសេចក្ដីចំរើនរុងរឿងឡើងដោយពុទ្ធានុភាព តែដែលសំខាន់
បំផុតក៏គឺកោះលង្កានិងខាងកស្មីរ ។

ព្រះមហិន្ទត្ថេរ និងព្រះនាងសង្ឃមិត្តាថេរី ជាឱរសនិងធីតារបស់
ព្រះបាទអសោក បានមកដល់ក្នុងកោះលង្កាហើយធ្វើឲ្យស្ដេចក្នុងលង្កា
ទ្វីបដែលទ្រង់ព្រះនាមថា ព្រះបាទទេវានម្បិយតិស្ស ជ្រះថ្លាក្នុងពុទ្ធោវាទ
ហើយសាសនារបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ក៏បានប្រតិស្ឋានក្នុងលង្កាទ្វីប
ក្នុងកាលពុទ្ធសករាជ ៣១៣ កាលដែលព្រះមហិន្ទត្ថេរ និងព្រះនាងសង្ឃ-
មិត្តាថេរីស្ដេចទៅលង្កាទ្វីបនោះ ទ្រង់បាននាំយកមែកពោធិ៍អំពីពោធិ-

ព្រឹក្សដែលព្រះសម្មាសម្ពុទ្ធត្រាស់នោះទៅដាំក្នុងកោះលង្កា ហើយដើមពោធិ៍នោះចំរើនធំឡើងនៅដល់មកសព្វថ្ងៃនេះ ជាឈើដែលរស់នៅបានយូរបំផុតក្នុងលោកមានអាយុជាង ២០១០ ឆ្នាំមកហើយ ។ កាលព្រះពុទ្ធសាសនាប្រតិស្ឋានមាំក្នុងកោះលង្កា ពួកជនអ្នកលង្កាក៏ខ្វល់ខ្វាយប្រឹងប្រែងក្នុងការតែងគម្ពីរនឹងប្រកាសព្រះពុទ្ធសាសនាទៅកាន់ប្រទេសភូមាផង នឹងឥណ្ឌូស៊ីនទាំងអស់ទៅ ហើយតមកក្នុងសម័យកណ្ដាល កាលព្រះពុទ្ធសាសនាបានខ្ចាត់ខ្ចាក់ចេញចាកឥណ្ឌា ដោយការបៀតបៀនរបស់សាសនាហិណ្ឌូនឹងមហាម៉ាត់ (អិស្លាម) ហើយកោះលង្កាក៏ត្រឡប់ប្រែជាប្រធានរបស់ព្រះពុទ្ធសាសនា ។

ចំណែកប៉ែកខាងជើង គឺខាងកស្មិរៈនឹងគន្ធារៈនោះព្រះសាវកជាអ្នកប្រកាសព្រះសាសនា បានធ្វើប្រយោជន៍ជាច្រើនជាងប៉ែកខាងឯទៀត ព្រោះថាព្រះមជ្ឈន្តិកៈ អ្នកនាំព្រះពុទ្ធសាសនាទៅប្រកាសក្នុងដែននោះបាននាំភិក្ខុប្រាំរយរូបទៅជាមួយផង ហើយពួកលោកទាំងអស់នេះបានធ្វើសេចក្ដីចំរើនមិនតែផ្លូវចរិយានឹងសីលធម៌របស់ប្រជាជនប៉ុណ្ណោះទេ លោកក៏បានទាំងណែនាំជួយក្នុងការសាងទីក្រុង, ធ្វើផ្លូវទឹក, ទំនុកបំរុងក្នុងការដាំដំណាំ, ឲ្យបានសេចក្ដីចម្រើនក្នុងផ្លូវរកចិញ្ចឹមជីវិតរបស់មនុស្សទៀតផង ក្នុងបទដែលពោលតទៅនឹងឃើញបានថា ខាងកស្មិរៈនឹងគន្ធារៈ

នេះឯងដែលជាអ្នកប្រកាសសាសនាចេញទៅកាន់ប្រទេសចិន ដែលបង្កើតជានិកាយមហាយានឡើង ។

សូម្បីព្រះបាទអសោកបានទំនុកបំរុងព្រះពុទ្ធសាសនាឲ្យរុងរឿងពេញបន្ទុកយ៉ាងនេះហើយ ក៏គង់មិនទាន់ពេញព្រះរាជហឫទ័យព្រះអង្គនៅឡើយ បានជាព្រះអង្គព្យាយាមធ្វើឲ្យព្រះពុទ្ធសាសនាផ្សាយចេញទៅដល់ប្រទេសក្រិក តាំងអំពីរជ្ជសម័យព្រះបាទអាឡេក្សាន្ទ្រមហារាជ ទឹងផ្សាយទៅដល់ទ្វីបអាហ្វ្រិកថែមទៀត ។ មានសិលាចារឹកចុះព្រះនាមស្តេចក្នុងប្រទេសផ្សេង ៗ ដែលជាអ្នកជួយក្នុងការប្រកាសសាសនា តែព្រះនាមរបស់ស្តេចទាំងអស់នោះ ព្រះបាទអសោកយកមកសរសេរជាភាសាបាលីទាំងអស់ ដូច អន្តិយកៈ (ព្រះបាទអែន្តិទុគោសទី ២ ជាស្តេចក្រុងសិរី (Sirie) តុរុមាយៈ (ព្រះបាទប៉តោលេមេ ជាស្តេចដែនដីអេហ្ស៊ីប្ត (Egypte) អន្តិកេនៈ (ព្រះបាទអន្តិគោន ជាស្តេចដែនដីម៉ាសេដ្វាន (Macédoine) អលិកសន្ទរោ (ព្រះបាទអឡេក្សាន្ទ្រ ជាស្តេចក្រុងអេប៉ីរ (Epire) មកៈ (ព្រះបាទមាគ័ស ស្តេចក្រុងនគរតូច ៗ មួយក្នុងដែនខាងកើតប្រទេសអេហ្ស៊ីប្ត) ដោយហេតុនេះទើបត្រូវរាប់ថាព្រះបាទអសោកបានប្រកាសព្រះពុទ្ធសាសនា មិនមានពុទ្ធសាសនិកជនឯណាឲ្យបានត្រឹមស្មើនឹងព្រះអង្គនោះឡើយ ហើយក្នុងគ្រានេះយើងក៏ចូលចិត្តបានថាហេតុអ្វីគោលសំខាន់ក្នុងគ្រិស្តសាសនាទើបប្រហែលគ្នានឹងព្រះពុទ្ធសា-

សនាដ៏ច្រើនម៉្លេះ ប្រសិនបើព្រះបាទអសោកមិនអស់ព្រះជន្មដោយរហ័ស ឬថាកាលអស់ព្រះជន្មហើយមានអ្នកប្រព្រឹត្តតាមព្រះរាជលំអានតមកដោយសេចក្ដីជ្រះថ្លាដ៏ហ្មត់ចត់ មានអំណាចរាជស័ក្តិយ៉ាងព្រះបាទអសោកផងហើយ ក៏មិនបាច់សង្ស័យទៀតឱរុបទាំងទ្វីបក៏នឹងកាន់ព្រះពុទ្ធសាសនាមិនខាន កាលបើឱរុបទាំងទ្វីបកាន់ព្រះពុទ្ធសាសនាហើយ ព្រះពុទ្ធ-សាសនាក៏នឹងត្រឡប់ជាទីពប់ញានរបស់លោកទាំងអស់ទូទៅ ទ្រង់ទ្រាយរបស់លោកហើយនឹងបែបផែនការងារប្រព្រឹត្តទៅនៃខែត្រផែនក៏នឹងខុសប្លែកចាកហេតុភេទក្នុងវេលានេះជាច្រើន ។

សិលាចារឹករបស់ព្រះបាទអសោក ដែលប្រតិស្ឋានទៅទីប្រសូតរបស់ព្រះពុទ្ធជាម្ចាស់ ដូចបានប្រែមកជាអក្សរខ្មែរនិងភាសាខ្មែរដូចតទៅនេះ :

១– ទេវានំ បិយេន បិយទសិន លាជិន វិសតិវសាភិសិតេន

២– អតន អាគាច មហីយិតេ ហិទ ពុធេ ជាតេ សក្យមុនីតិ

៣– សិលាវិគឌភីចា កាលាបិត សិលាថំភេច ឧសបាបិតេ

៤– ហិទ ភគវំ ជាតេតិ លុំមិនិគាមេ ឧពលិកេ កដេ

៥– អឋភាគិយេច

## ពាក្យប្រែ

១ - ព្រះរាជាបិយទសីជាទីស្រឡាញ់របស់ទេវតា រាជាភិសេកហើយបាន ២០ ឆ្នាំ[១] ។

២ - ស្តេចមកបូជាដោយព្រះអង្គឯង ទ្រង់ជ្រាបច្បាស់ថា ព្រះសក្យមុនីពុទ្ធទ្រង់ប្រសូតហើយក្នុងទីនេះ ។

៣ - ទើបប្រោសឲ្យចារកសិលាទុក?[២] និងប្រោសឲ្យតាំងសសរថ្ម ។

៤ - សំដែងប្រាប់ថា ព្រះដ៏មានព្រះភាគទ្រង់ប្រសូតហើយក្នុងនេះ និងប្រោសឲ្យបន្ថយសួយប្អូន ក្នុងតំបន់ស្រុកលុម្ពិនី ។

៥ - ចុះប្រាំបីភាគ (?) ។

# អសន្ធិមិត្តាអគ្គមហេសី

### គម្ពីរមហាវង្ស

ព្រះបាទអសោកមហារាជទ្រង់មានអគ្គមហេសីមួយអង្គ ព្រះនាមនាងអសន្ធិមិត្តា[៣] (មានអវយវៈឥតស្នាមដំណា) ព្រះនាងមានរូបឆោមដ៏ល្អជាដើមក្នុងលោក គួរអ្នកផងក្រឡេកមើលដោយសេចក្តីពេញចិត្ត ព្រះ

---

១ ព្រះនាមពេញរបស់ព្រះបាទអសោកថា "អសោកបិយទសី" ។ ២ ដែលមានគ្រឿងសំគាល់ផ្កាប្រេះឲ្យដឹងថា អ្នកប្រែមិនស្គាល់ច្បាស់ ។ ៣ តាមសៀវភៅពុទ្ធសាសនារបស់លោកល្វី-ហ្វី ណូត៍ ដែលលោកជុំ-មៅប្រែជាខ្មែរថា ព្រះនាងអសន្ធិមិត្តាមានបុត្រមួយព្រះអង្គ ព្រះនាមកុណាល តែក្នុងមហាវង្សមិនឃើញមាននិយាយ ។

នាងមានបសាទសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា តែងនិមន្តព្រះភិក្ខុសង្ឃទាំងប្រាំមួយម៉ឺនអង្គមកប្រគេនចង្ហាន់ជាមួយនឹងព្រះបាទអសោកជាព្រះរាជស្វាមី ។

ថ្ងៃមួយ ព្រះនាងប្រថាប់នៅលើ(កៅអីមាសជាំត្បូង) កំពុងសោយអំពៅដែលពួកទេវតានាំយកពីហិមវន្តប្រទេសមកថ្វាយ ពេលនោះព្រះបាទអសោកស្តេចយាងចូលទៅក្នុងទីនោះទ្រង់ទតឃើញព្រះនាងអសន្ធិមិត្តាកំពុងសោយអំពៅ ទើបចំអន់ព្រះនាងត្រាសព្រះរាជហឫទ័យថា "ហៃនាងមានរូបឆោមទឹកក្រៅដ៏ល្អស្រស់ប្រិមប្រិយ នាងបរិភោគនូវទឹកអំពៅដ៏ផ្អែមត្រជាក់ដូចជារសនៃទឹកឃ្មុំនេះសប្បាយរីករាយចិត្តណាស់ទៅឬ?" ។

ព្រះរាជទេវីបានស្តាប់ព្រះរាជឱង្ការត្រាស់សរសើរចំអកដូច្នោះក៏តបព្រះហឫទ័យក្រាបទូលថា: "បពិត្រព្រះសម្មតិទេពដ៏ប្រសើរ អំពៅនេះកើតក្នុងហិមវន្តប្រទេស ទេវតានាំយកមកថ្វាយនេះ ព្រោះតែបុញ្ញានុភាពនៃខ្ញុំម្ចាស់ មិនមែនព្រោះបុណ្យសម្ភារនៃព្រះអង្គទេ" ។

ព្រះមហាក្សត្រិយ៍ត្រាស់តបថា: "នៃនាងមានកក្តីដ៏ចំរើន ឥស្សរិយសម្បត្តិក្នុងសកលជម្ពូទ្វីបនេះជារបស់យើង នាងថាសម្បត្តិទាំងពួងកើតព្រោះបុណ្យរបស់នាងទៅវិញ នាងឯងរាយបុកស្មោ លើកដំកើងខ្លួនឲ្យខ្ពស់ផុតកំពូលមហាព្រហ្ម ប្រនោកបុណ្យរបស់យើងទំលាក់ឲ្យទាបដល់អវិចីមហានរកទៅឬ? នាងឯងថាសម្បត្តិកើតព្រោះបុណ្យខ្លួននាង

ឯង១មានបុណ្យពិតណាស់ហើយ បើដូច្នោះព្រឹកនេះ យើងនឹងលៀងព្រះសង្ឃប្រាំមួយម៉ឺនអង្គ ចូរនាងឯងរកសំពត់ឲ្យបានប្រាំមួយម៉ឺនផាប់នឹងប្រគេនដល់ព្រះភិក្ខុសង្ឃក្នុងថ្ងៃព្រឹកនេះ បើនាងឯងរកបានទាន់ពេលធ្វើទាននេះ ទើបឃើញជាក់ច្បាស់ថានាងមានបុណ្យប្រាកដមែន តែបើរកមិនបានទេ យើងនឹងត្រូវធ្វើតាមរាជអាជ្ញាដល់នាងឯងក្នុងថ្ងៃព្រឹកនេះ" ។

កាលនាងទេវីបានស្តាប់ព្រះរាជឱង្ការដាក់រាជអាជ្ញាដល់នាង ក៏ភិតភ័យមានព្រះកន្ត្រឹតស្ទាំងដោយរំពឹងថា "ព្រះមហាក្សត្រិយ៍ទ្រង់ព្រះក្រោធដល់អាត្មា" ហើយព្រះនាងសោយសោកហាក់ដូចជាត្រូវថ្នាំពិស ពុំបើក្តៅក្រហល់ជាប់នៅនឹងដួងហឫទ័យភ័យជានិច្ចគ្រប់ដង្ហើមចេញចូល ព្រះនាងរំពឹងថា "នុអាត្មាអញនេះ នឹងទៅរកសំពត់ក្នុងទីឯណាឲ្យបានដល់ទៅប្រាំមួយម៉ឺនដូច្នេះហ្ន៎" ព្រះនាងចូលទៅក្នុងក្រឡាព្រះបន្ទំយំទួញចម្រែះទទៀលទៅមក ៗ លើទីសិរីសេយ្យាមិនបាននិទ្រាលក់អស់មួយរាត្រី ដោយថប់បារម្ភថា មុខជានឹងត្រូវស្លាប់ព្រឹកនេះ ហេតុតែតេជះកុសលដែលនាងបានកសាងមកអំពីអតីតជាតិ ក៏ក្តៅដល់ចតុលោកបាលទាំង[១] ៤ គ្រានោះស្តេចវេស្សវ័ណមហារាជបានជ្រាបថា ព្រះនាងអសន្ធិមិត្តាអគ្គមហេសីមានទុក្ខព្រួយដូច្នោះ ក៏ស្តេចចូលទៅកាន់សំណាក់ព្រះ

---

១ ចតុលោកបាល ទេវតារក្សាលោកមាន ៤ អង្គ គឺ កុវេរៈ (ឬវេស្សវ័ណក៏ហៅ) ធតរដ្ឋ វិរូបក្ខនិងវិរុឡ្ហក ។ ទេវតាទាំង ៤ អង្គនេះជាអ្នកដឹងថា សត្វធ្វើល្អធ្វើអាក្រក់គ្រប់យ៉ាង ។

នាងហើយត្រាស់ថា: "បពិត្រព្រះរាជទេវី ព្រះនាងកុំសោយសោកថប់ បារម្ភឡើយ សំពត់សាដករបស់ព្រះនាង កាលថ្វាយដល់ព្រះបច្ចេកពុទ្ធ អំពីជាតិមុននោះ ចូរព្រះនាងពិចារណាពីផលសំពត់សាដករបស់ព្រះនាងនោះចុះ នឹងឲ្យផលប្រាកដដល់ព្រះនាងគ្រានេះ" លុះទ្រង់ដាស់តឿនព្រះស្មារតី ព្រះអគ្គមហេសីដូច្នេះ ហើយក៏និម្មិតដោយឫទ្ធិ នាំយកប្រអប់មួយមានដាយសំពត់សាដកចេញមកប្រាកដខាងក្រៅ ប្រគល់ឲ្យព្រះនាងអសន្ធិមិត្តាពជទេវី ហើយត្រាស់បង្គាប់ថា "បពិត្រព្រះរាជទេវី បើព្រះនាងប្រាថ្នានឹងចង់យកសំពត់សាដកប៉ុន្មានៗ ក្តី ចូរទាញទាញដាយសំពត់ដែលចេញមកប្រាកដខាងក្រៅនេះចុះ នឹងកើតសំពត់សាដកយ៉ាងល្អវិសេសដូចចិត្ត មានដំរៃទ្បនឹងកាត់ថ្លៃមិនបានប្រមាណមិនកើត" ។ លុះព្រះបាទវេស្សវ័ណមហារាជត្រាស់បង្គាប់ព្រះនាងសព្វគ្រប់ហើយ ក៏ស្តេចចេញពីទីនោះទៅ លុះដល់ព្រឹកព្រលឹមស្រាងឡើង ព្រះបាទអសោកស្តេចអង្គាសព្រះភិក្ខុសង្ឃដោយភោជនាហារដ៏ឧត្តម បូជាដោយសុគន្ធបុប្ផាស្រេចហើយ ក៏ចៀងព្រះនេត្រទតមើលព្រះអគ្គមហេសីត្រាស់ថា "ចូរនាងយកសំពត់ប្រាំមួយហ៊ឺនផាប់តាមដោយកំឡាំងបុណ្យរបស់ខ្លួនមកនឹងប្រគេនដល់ព្រះសង្ឃប្រាំមួយហ៊ឺនរូបនេះ" ។ ព្រះរាជទេវីក៏នាំយកប្រអប់ទិព្វមកទាញហូតយកសំពត់ម្តងមួយគូៗ ជាសំពត់កាត់

ថ្ងៃមិនបាន ហាក់ដូចជាសំពត់ទិព្វដែលកើតក្នុងដើមកល្បព្រឹក្ស ថ្វាយដល់ព្រះមហាក្សត្រិយ៍ ហើយក្នុងសំពត់មួយផាប់ៗ នោះល្មមបានចីវរមួយត្រៃៗ ព្រះមហាក្សត្រិយ៍ទ្រង់ប្រទានដល់ព្រះសង្ឃថេរ ហើយទើបថ្វាយទូទៅគ្រប់ព្រះសង្ឃទាំងប្រាំមួយហ្មឺនរូបដែលគង់នៅក្នុងទីនោះ ព្រះសង្ឃទាំងអស់អនុមោទនា ហើយថ្វាយព្រះពរលោ ព្រះមហាក្សត្រិយ៍ពេញទៅកាន់អាកាស ។

ឯព្រះបាទអសោកទ្រង់សព្វព្រះរាជហឫទ័យសប្បាយរីករាយស្ញើចនឹងបុណ្យកុសលនៃព្រះនាងទេវី ត្រាស់ស្រស់ស្រាយដោយសេចក្ដីសោម-នស្ស ទើបស្ដេចទ្រង់ឈរក្នុងកណ្ដាលប្រជុំពួកស្រីស្នំដ៏រុងរឿងដូចជាព្រះឥន្ទ្រនៅក្នុងកណ្ដាលពួកស្រីទេពអប្សរក្នុងស្ថានសួគ៌ ហើយត្រាស់ថា "នៃនាង! ខ្ញុំបងនេះមានសេចក្ដីជ្រះថ្លាក្នុងកុសលរបស់នាងពន់ពេក យើងដឹងច្បាស់ហើយថា កុសលនាងបានធ្វើទុកមកអំពីជាតិមុនពិតទើបបានមកជួបប្រសពនឹងយើងៗ ធ្វើអាការកិរិយាដល់នាងទាំងនេះ ដើម្បីទំនុងល្បងកុសលរបស់នាងមើល នាងកុំតូចចិត្តឡើយ ចូរអត់ទោសចុះ ឥស្សរិយសម្បត្តិទាំងពួងនេះយើងប្រគល់ឲ្យដល់នាងហើយ ចូរនាងជាធំចម្បងជាងពួកស្រីស្នំទាំងមួយហ្មឺនប្រាំមួយពាន់នេះ ចាប់ដើមតាំងតែពីថ្ងៃនេះទៅ" ។

( នៅមានត )

# ប្រស្នាចំរើនសតិបញ្ញា

## ប្រស្នាទី ១

## សេចក្ដីឆ្លើយទី ២

សួរថា: ខ្វាក់នឹងខ្វិនតើណាគ្រាន់បើជាង?

ក្នុងប្រស្នានេះមានសេចក្ដីមុខគួរឲ្យចង់ស្ដាប់ណាស់ ខ្វាក់ឬខ្វិនពីរ ចំពូកនេះ គោងមានកំណត់ទាំងសងខាង ៗ ឯបំណងរបស់ខ្ញុំបាទ ក្នុងការដោះស្រាយប្រស្នានេះត្រូវការកំណត់ថា ពាក្យថា "ខ្វាក់" គឺខ្វាក់ ទាំងសងខាងមើលអ្វីមិនឃើញសោះ តែដៃ ជើង ត្រចៀក នៅល្អគ្រប់ គ្រាន់ ៗ ពាក្យថា "ខ្វិន" គឺខ្វិនជើងទាំងសងខាងដើរទៅណាមិនរួច ឡើយ តែត្រចៀកដៃភ្នែកនៅល្អទាំងអស់ ហើយត្រូវកំណត់ថា អ្នក ទាំងពីរនេះឥតអ្នកណាទំនុកបំរុងថែរក្សាទេ គោងចិញ្ចឹមជីវិតដោយទំនើង ខ្លួនឯង ៗ បើមានសភាពដូច្នោះ ខ្ញុំបាទយល់ថា អ្នកខ្វាក់ភ្នែកទាំង សងខាងគ្រាន់បើជាងអ្នកខ្វិនជើងទាំងសងខាង ព្រោះភ្នែកខ្វាក់មើលអ្វីមិន ឃើញក៏ពិតមែន តែការសំខាន់នៅត្រង់ជើងទាំងសងខាងនៅល្អទាំង អស់ ល្មមជាគ្រឿងចិញ្ចឹមជីវិតដោយខ្លួនឯងបាន ទំងដើរសុំទានគេឬ ច្រៀងសុំទានក៏បាន ដូចតាយូនម្នាក់ ខ្វាក់ភ្នែកទាំងសងខាង ចេះកូតទ្រ ចេះច្រៀង មានក្មេងតូចម្នាក់ដឹកដៃដើរសុំទាននៅទីប្រជុំបុណ្យផ្សានឬនៅ

ទីផ្សារ គាត់បេះក្បូតទ្រ បេះប្រៀង មានមនុស្សតែងតែមកឈរមើលឈរ
ស្តាប់ជុំៗជាច្រើន បោះសេនបោះកាក់ឲ្យជាទាន ក្នុង ១ ថ្ងៃៗបានប្រាក់
កាសល្មមចិញ្ចឹមជីវិតបានដោយស្រួលមិនលំបាកវេទនាប៉ុន្មានទេ ។ បណ្តា
មនុស្សយើងទាំងមានទាំងក្រ តែខ្វាក់ខ្វិនខូចដៃជើងហើយ រមែងមាន
សេចក្តីត្រូវការតែអាហារមួយចំណែកៗ ក្នុងមួយថ្ងៃៗដូចជាសត្វទាំងឡាយ
តែអ្នកដែលខ្វិនខូចជើងទាំងសងខាងឥតអ្នកទំនុកបំរុងហើយ តែងដល់នូវ
សេចក្តីវិនាស ព្រោះទឹងដើរទៅសុំទានគេឬទៅរកស៊ីឈ្នួលគេក៏មិនបាន
អស់ផ្លូវរកចិញ្ចឹមជីវិតដោយទំទើងខ្លួនបាន ។ ឯអ្នកភ្នែកខ្វាក់តែជើងដៃនៅ
ល្អទាំងអស់ ទុកជាមិនបេះផ្កាក្បូតទ្រ ឬប្រៀងជាដើម ក៏ល្មមប្រើជើងដើរ
ទៅសុំទានគេចិញ្ចឹមជីវិតរបស់ខ្លួនបានដែរ មិនលំបាកវេទនាដូចជាមនុស្ស
ខ្វិនជើងទេ ។ ហេតុនេះទើបខ្ញុំបាទយល់ថា អ្នកខ្វាក់ភ្នែកគ្រាន់បើជាង
អ្នកខ្វិន ៗ មួយវិញទៀត បើមានគ្រោះថ្នាក់អន្តរាយយ៉ាងធំមកយ៉ាង
ទាន់ហន់ ចួនជាអ្នកខ្វាក់នឹងអ្នកខ្វិននៅក្នុងទីនោះជាមួយគ្នា ដូចជាមាន
ថយន្តឬសេះដ៏រគោក្របីជាដើមរត់ចូលមកជិត ។ មុខជានឹងជាន់ឬកិនអ្នក
ទាំងពីរ អ្នកខ្វិនទុកជាមានភ្នែកមើលឃើញត្រចៀកស្តាប់ឮ ក៏មិនអាចគេច
រត់ឲ្យផុតអន្តរាយទៅបាន គោងទទួលគ្រោះថ្នាក់ជាដាច់ខាត ។ ឯអ្នក
ខ្វាក់ទុកជាភ្នែកមើលមិនឃើញតែត្រចៀកស្តាប់ឮ ក៏អាចនឹងគេចរត់ឲ្យ
ផុតអន្តរាយទៅបាន ១ គ្រា មិនដល់ទាល់ច្រកដូចអ្នកខ្វិនទេ នេះក៏ជា

ឧទាហរណ៍ ១ បង្ហាញឲ្យឃើញថា តើខាងណាត្រាំបជាងខាងណា អ្នកដែលបំណុលយឲ្យវេចគិនឬសត្វជាំត្រាំបជាង ឬអ្នកដែលគេបតគេឲ្យផុតអន្ទាក់យ៉ាងនោះបានត្រាំបជាង ដូច្នោះគួរយល់ថាខ្លាកត្រាំបជាងខ្វិនដូចសេចក្តីដែលពណ៌នាមកនេះ ។

នាយខ្លាក់

*

* *

ប្រស្នាទី ២

សួរថា: សត់នាំឲ្យបានសុខប៉ុណ្ណានទុក ?

ក្នុងប្រស្នានេះ ខ្ញុំបាទបានត្រិះរិះពិចារណាអំពីធម្មតារបស់សត់តែងកើតមកប្រចាំរូបកាយរបស់មនុស្សទូទៅ យល់ឃើញថាជាគ្រឿងនាំឲ្យកើតទុក្ខរំខានចិត្តឥតស្រាកស្រាន្ត គ្រាន់តែខុសគ្នាត្រង់តិចឬច្រើនប៉ុណ្ណោះ ។ ធម្មតាសត់ស្កូតបរិបូណ៌ អ្នកម្ចាស់សត់គោងតែខំស្រាហ៍ទុកបំរុងឲ្យរៀបរយ គឺគោងកក់ គោងសិត គោងកាត់ជានិច្ច បើមិនកាត់សោះពោះបង់ទុកឲ្យវែងមិនស្អិតស្អាងទេ មុខជាឆេះឆាបកើតចៃចង្រៃក្បាលមិនខាន ដូច្នេះ អ្នកម្ចាស់សត់ត្រូវតែខំរកខ្វាយរកគ្រឿងស្អិតស្អាងឲ្យសត់ស្អាតល្អ គឺ ក្រមួន, ប្រេងដូង, ក្រាស, កញ្ចក់, កាំបិតកោរ, កន្ត្រៃ ជាដើមអស់នេះបំរុងទុកជានិច្ច ។ កាលណាសត់ដុះវែងបន្តិចឡើង ដោយហេតុ

ទៅក្នុង ១ ខែគេតែងទៅជួលជាងកាត់សក់ឬកាល់ជើងសក់ម្ដង គេតែងបង់ខាត
សោហ៊ុយម្ដងយ៉ាងតិចត្រឹម ២ កាក់ ឬគ្រាន់តែបៀរជើងសក់ម្ដងថ្លៃ១ កាក់
បើហៅគេមកកាត់ឯផ្ទះ គេតែងបង់ថ្លៃកាត់សក់យ៉ាងតិចត្រឹម ៣ កាក់រហូត
ដល់ ៥ កាក់ ១ រៀលក៏មាន អ្នកខ្លះនិយមកាត់សក់ដល់ ២ ដងឬ ៣ ដង
ក្នុង ១ ខែក៏មាន គេតែងបង់ខាតប្រាក់កាសរឿងសក់ កាន់តែច្រើនឡើង
ទៅទៀត ។

មួយវិញទៀត កាលបើមានដំណើរចេញពីផ្ទះទៅ ច្រើនតែនាំ
ឲ្យយឺតយូរខូចពេលវេលា ពីព្រោះគេតែងលាបប្រេងសិតសក់ឲ្យរៀបរយ
ជាមុនសិនទើបទៅបាន ។ សក់នេះមានតែនាំឲ្យបង់ខាតប្រាក់កាស ទីង
នាំឲ្យកើតកង្វល់ដោយការស្អិតស្អាងបំរុងជានិច្ច ទើបខ្ញុំបាទយល់ថា សក់
នេះមានតែនាំឲ្យកើតទុក្ខព្រួយតែម្យ៉ាង ។ តែដែលពោលមកនេះហាក់ដូច
ជាសំដៅទីងទាស់នឹងសេចក្ដីនិយមរបស់មនុស្សលោកខ្លាំងណាស់ ព្រោះ
មនុស្សលោកស្រឡាញ់សក់ល្អគ្រប់គ្នា មិនខ្វាចនឿយហត់ក្នុងការស្អិត
ស្អាងសក់នោះឡើយ បើបែរជាសក់វិបត្តិទៅឬគ្រាន់តែស្កើងបន្តិចទៅ រុះ
ខ្លះទៅ ឬមានពណ៌ខុសប្រក្រតីទៅ ឆ្លុះកញ្ចក់មើលវេលាណាក៏ដកដង្ហើម
ធំតែម្ដងដោយទឹកស្ដាយសក់របស់ខ្លួន ទើបឃើញថាមនុស្សលោកមិន
ខ្វាចនឿយហត់ឬបង់ខាតក្នុងការស្អិតស្អាងសក់ទេ តែងមានទុក្ខព្រួយចិត្ត

នឹងសក់ដែលវិបត្តិប្រែប្រួលទៅនោះច្រើនជាង ដល់ទៅខំបណ្ដុះសក់ឲ្យផ្លាស់ពីពណ៌ប្រក្រតី ទុកជាបង់ខាតថ្លៃថ្នាំយ៉ាងណាក៏សុខចិត្ត ។

ហេតុដូច្នេះទើបឃើញថា សក់នាំឲ្យកើតទុក្ខរំខានចិត្តតាំងអស់ តែសូមសរុបដោយខ្លីៗថា សក់អស់ទៅក៏មិនល្អ សក់មានក៏បង់សោហ៊ុយ ។

អវត្ត

*

* *

## ប្រស្នាជាគំរប់ ៣

សួរថា: ស៊ីស្លានឹងដកប៉ារី តើគួរតមយ៉ាងណាមុន ?

### សេចក្ដីឆ្លើយ ទី ១

ការស៊ីស្លានឹងដកប៉ារី តើគួរតមគួរវៀរយ៉ាងណាមុន រឿងនេះលំបាកនឹងវិនិច្ឆ័យណាស់ ព្រោះស្លានឹងប៉ារីនេះជាទំនិយមរាប់អានរបស់ជនជាតិខ្មែរទូទៅ វេលាមានបុណ្យទានអ្វីគេតែងប្រើស្លាប៉ារីជាត្រីមុខ តែមានអ្នកខ្លះចូលចិត្តប៉ារីជាងស៊ីស្លា ខ្លះចូលចិត្តស្លាជាងប៉ារី ជា នានាចិត្ត ដូច្នេះៗ ក្នុងសម័យសព្វថ្ងៃនេះ ជនទាំងប្រុសទាំងស្រីនិយមដកប៉ារីថ្នាំប៉ាកាំងច្រើនជាងស៊ីស្លា ។ កាលពីដើមនោះប្រុសៗច្រើនដកប៉ារី ស្រីៗច្រើនស៊ីស្លា

តែកាលបើពិនិត្យពិចារណាដោយសព្វគ្រប់ទៅទើងឃើញថា ការជក់បារីល្អជាងស៊ីស្លា ព្រោះការស៊ីស្លានាំឲ្យកើតទោសច្រើនប្រការ គឺប្រការ ១ លំបាកក្រោខ្លួនប្រាណទឹងសំពត់អាវឲ្យបានស្អាត ដ្បិតវេលាដែលមានស្លានៅក្នុងមាត់ហើយ កាលទឹងស្ដោះទឹកមាត់នោះរមែងខ្ចាយទឹកមាត់ទៅប្រឡាក់សំពត់អាវប្ដូរខ្លួនប្រាណ បើប្អូនជាមិនប្រយ័ត្ន ប្រការ ១ ទៀតវេលាធ្វើការនៅប៊ុយរ៉ូ បើអ្នកស៊ីស្លាចេះក្រោបកពារកិរិយា ក៏ត្រាន់បើបន្តិចប្រយ័ត្នមិនឲ្យប្រឡាក់ទីកន្លែងធ្វើការ បើជាអ្នកមិនមានកិរិយាល្អផង ក៏មុខជាទើងអង្គុយស្ដោះ ឈរស្ដោះផ្ដេសផ្ដាស ក្រហមច្រាលដោយទឹកមាត់មុខគ្រួរឆ្ពឹម ៗ មនុស្សបែបនេះ លុះតែមានកន្ទោរតាំងរៀងរាយសងខាងចិញ្ចើមថ្នល់គ្រប់ៗ ផ្លូវទើបផុតខ្ទិល ៗ បើជាអ្នកពជការទៅធ្វើការក្នុងប៊ុយរ៉ូ ហើយបៀមស្លានៅក្នុងមាត់ផង តែភ្លេចខ្លួនមុខជាធ្លាក់កាកស្លាប្ដូរទឹកមាត់ស្លាក្រហមប្រឡាក់ក្រដាសសរសេរ ឬទីកន្លែងធ្វើការមិនខាន នេះក៏សឲ្យឃើញទោសនៃការស៊ីស្លា ១ យ៉ាង ៗ បើជក់តែបារីមិនស៊ីស្លាទេទុកជាគោះកំទេចបារីធ្លាក់ជ្រុះទៅលើ ប្រោសផ្ទុំចេញក៏ស្អាតបានដោយងាយ បើបែរជាប្រឡាក់ទឹកមាត់ស្លាវិញ មិនងាយទឹងដុសលាងឲ្យស្អាតបានដោយងាយះឡើយ ហេតុដូច្នោះ ទើបខ្ញុំបាទយល់ថាគួរតមស្លា ជក់បារីវិញល្អជាង ៗ

ស្លា-បារី

*

*   *

# ប្រស្នាជាគំរប់ ៤

*សួរថា: មានពុកមាត់គួរកោរចេញ ឬគួរទុកឲ្យវែងទៅល្អជាង?*

## សេចក្តីឆ្លើយទី ១

ការទុកពុកមាត់និងកោរចេញ តើខាងណាស្រួលជាង? រឿងនេះ ខ្ញុំបាទនឹងសូមថ្លែងតាមយោបល់របស់ខ្លួនដូចមានតទៅនេះ គឺពីដើមប្រ-ទេសក្រិកនិងបារាំង មនុស្សចូលចិត្តទុកពុកមាត់ពុកចង្កា ប្រទេសក្រៅពីនេះ កោរឬកាត់ទុកតែខ្លីៗ ក៏មាន តាមសេចក្តីនិយមចូលចិត្តរបស់គេ បើគេមានទុក្ខព្រួយដល់ទាល់ប្រកក៏កាត់ឬកោរចេញក៏មាន ដូចរឿងបួចទាល់ប្រកជាដើម ។ នៅប្រទេសខ្មែរកាលពីសម័យបុរាណ ទុកពុកមាត់វែងៗ ហើយពត់ជាស្នែងក្របីក៏មាន កោរឬកាត់ខ្លីក៏មាន តែមិនបានទុកពុកមាត់ពុកចង្កាវែងស្កុកស្កាញ ដូចឫសីតាបសដែលមានរឿងដំណាលថា តាបសឥសីទុកពុកចង្កាវែងស្កូញស្កាញអង្គុយឈាន ពួកសត្វចាបចូលទៅធ្វើសំបុកនៅដូច្នោះទេ ។ ឯយោបល់ខ្ញុំបាទយល់ថា កោរចេញក៏មិនល្អ ទុកវែងពេកក៏មិនល្អដែរ បើមានពុកមាត់គួរកាត់តាក់តែងឲ្យស្អាតរៀបរយ ទើបជាការសមគួរ មិនគួរកោររលីងទេ ព្រោះអ្នកដែលមានពុកមាត់នោះ បើគាត់តែងឲ្យត្រូវបែបផែន ក៏មើលឃើញស្រស់បស់សមជាកូនប្រុសមែន បើធ្វើជាទាហានផង កាន់តែមើល

ឃើញសំប៉ើមឡើងទៀត ។ ឯអ្នកដែលកោរពុកមាត់រលីងចេងនោះ គន់មើលមុខមាត់មិនស្រស់ឡើយ ដូចមុខស្រី វៀរលែងតែអ្នកដែលឥតពុកមាត់មកពីកំណើតក៏ល្មើយទៅចុះ ព្រោះសង្ខាររាងកាយរបស់គេភាគតែងមកដូច្នោះឯង មិនគួរទៅត្អះតិះដៀលគេទេ តែឯអ្នកដែលមានពុកមាត់ពុកចង្កាហើយ ទឹងទុកឲ្យវែងស្កុយមិនកាល់កាត់ឲ្យមានរបៀបរៀបរយក៏មិនល្អមើលដែរ ដ្បិតជួនកាលវេលាដែលបរិភោគអាហារ ទឹងប្រឡាក់សម្លបាយឬទឹកសម្ល ឬគ្រាប់បាយជាប់ពុកមាត់ពុកចង្កាក៏មិនល្អមើលដែរ ។ មួយវិញទៀត វេលាជក់បារីដល់បារីជក់ឆេះជិតដល់គល់ ទឹងកាលទៅឆេះពុកមាត់ឈ្មៀមឡប់មិនខាន ។ ហេតុដូច្នោះទើបខ្ញុំបាទយល់ថា ពុកមាត់គ្រាន់តែទុកឲ្យល្អមើលសមភេទជាប្រុសប៉ុណ្ណោះ តែកុំទុកឲ្យវែងស្រកាកដូចឥសីនៅព្រៃហេមពាន្តនុ៎ះទេ ។

អ្នកកណ្ដាល

# រឿងបុរសបាញ់ទុង

មានទំនានមួយដំណាលថា នៅស្រុកមួយនោះ មានបុរស ២នាក់ ម្នាក់ឈ្មោះចៅសោកែ ម្នាក់ទៀតឈ្មោះចៅពាលោ ។ តែងទៅរករៀនមន្តអាគមសិល្បសាស្ត្រចេះហើយ ទើបចៅពាលោរកឧបាយកលចំហូរទ្រព្យរបស់គេមកជារបស់ខ្លួន ។

មានកាលសម័យថ្ងៃ ១ នោះ ចៅសោកែបានចេញទៅបាញ់ទុងបានមួយ ។ ឯចៅពាលោគិតថា សោកែគាត់នឹងជូនសាច់ទុងអញស៊ីផងទេឬអេះ បើគាត់មិនជូនសាច់ទុងអញស៊ីទេ អញនឹងរករឿងគាត់ឲ្យកើតជាក្តីឡើងក្នុងម្តងនេះឯង ។ ឯចៅសោកែស្ងអាំងសាច់ទុងរួចស្រេចបរិភោគទៅ ពុំបានជូនចំណែកទៅចៅពាលោឡើយ ។ ទើបចៅពាលោទៅប្តឹងចៅក្រមឲ្យកោះចៅសោកែយកទៅជំនុំជំរះ ឯពាក្យដែលចៅពាលោប្តឹងចៅក្រមនោះថា កាលអាពុកខ្ញុំប្របាទឈឺថ្កាត់នោះគាត់ផ្តាំនឹងខ្ញុំប្របាទថា បើគាត់ស្លាប់ទៅនឹងទៅយកកំណើតជាសត្វទុង ដោយដូរចំបួរមេបារៀង ៗ មក សឹងស្លាប់ទៅកើតជាទុងទាំងអស់ បើមានអ្នកណាមួយទៅបាញ់ទុង ឲ្យប្តឹងចៅក្រមឲ្យចាប់យកទៅជំនុំពិរចាណា លក់ពិន័យ តាមដោយនូវច្បាប់សម្លាប់គេ ៗ ឥឡូវនេះចៅសោកែសម្លាប់អាពុកខ្ញុំស៊ី ហេតុនេះ សូមប្របាទម្ចាស់កាត់សេចក្តីឲ្យទានខ្ញុំប្របាទហោង ។

ឯចៅសោកែឆ្លើយដោះសាថា អាពុកម្តាយខ្ញុំស្រដីប្រាប់ខ្ញុំរៀងៗ មកថា មេបាដីដូនជីតាអាពុកម្តាយ អម្បាលដែលស្លាប់ទៅសឹងទៅយកកំណើតជាត្រី ហើយផ្តាំថា បើក្រែងមានសរពើសត្វអ្វីទៅសម្លាប់អស់សត្វត្រីស៊ីហើយ ឲ្យខ្ញុំប្រយាទបាញ់សម្លាប់សត្វអស់នោះស៊ីវិញហោង ៗ បើសត្វអស់នោះ មានកូនចៅផៅពង្សនៅជាមនុស្សឲ្យប្តឹងចៅក្រមឲ្យចាប់យកមកជំនុំជំរះ លក់ពិន័យកូនចៅផៅពង្សអស់នោះហោង ៗ ឥឡូវនេះ ហ្វូងទុងនាំគ្នាទៅបួនចាប់ត្រីជាដីដូនជីតាអាពុកម្តាយខ្ញុំប្រយាទស៊ី ទើបខ្ញុំប្រយាទបាញ់ទុងអស់នោះ ៗ ឥឡូវ ចៅពាណោថាទុងនោះជាអាពុកគេដូច្នេះ សូមអស់លោកជាចៅក្រមជំនុំពិចារណាសេចក្តីនេះឲ្យទានខ្ញុំប្រយាទចុះ ៗ

ឯអស់ចៅក្រមជំនុំពិចារណាសេចក្តីនេះមិនដាច់ស្រេចទើបនាំចៅទាំងពីរឡើងទៅក្រាបបង្គំទូលសម្តេចព្រះមហាក្សត្រ តាមដំណើរសេចក្តីនោះសព្វគ្រប់ប្រការ ៗ ឯចៅពាណោឃើញថា ក្តីរបស់ខ្លួនចាញ់ប្រៀបក្តីរបស់ចៅសោកែ ទើបនិយាយដោះសាខ្លួនថា ចៅសោកែថាពុំបានបាញ់ទុងនៅអាយឡើយ បាញ់ទុងមកពីនាយទេ ទូលបង្គំជាខ្ញុំជានាប្រកាន់ត្រង់នេះឯង ៗ

សម្តេចព្រះមហាក្សត្រមានព្រះបន្ទូលដណ្តឹងសួរចៅពាលោថា ឯទុងអាពុកចៅនៅអាយស៊ីអ៊ី ស៊ីក្តាមខ្យងប្តុស៊ីត្រី ។ ចៅពាលោក្រាបទូលថាស៊ីត្រី ។ ទើបព្រះអង្គមានព្រះបន្ទូលថា បើដូច្នោះ អាពុកចៅតែងចាប់ត្រីជាអាពុកចៅសោកែស៊ី សមដូចពាក្យចៅសោកែមែន ។ ទ្រង់បង្គាប់ឲ្យលក់ចៅពាលោជាខ្ញុំចៅសោកែ ។ ចៅទាំងពីរក៏សុខចិត្តក្រាបទូលលាត្រឡប់ទៅកាន់លំនៅអាត្មាវិញហោង ។

ចប់រឿងបុរសបាញ់ទុងតែប៉ុណ្ណោះ ។